# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

---

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ឧកញ៉ាភក្តីសាទេព កែ-នេត... រឿងសុមនមាលាការ (ពាក្យកាព្យ)..... ៤៥១
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម... សេចក្តីសង្ខេបអំពីគោលផ្សេងៗ នៃពង្សាវតារខ្មែរ (តមក)............ ៤៦៤
" " " ពង្សាវតារប្រទេសចិន (តមក)...... ៤៧៣
ឧកញ៉ា ទេពពិទូរ-ក្រសេម.... វណ្ណគតិ នារាយណ៍ ទសាវតារ (តមក).. ៤៧៨
ឃុនឧត្តមប្រីជា ចាប-ពិន.. អធិប្បាយសុភាសិតខ្មែរ (តមក)..... ៤៨៣

*ផ្នែកសាសនា*

ព្រះបាឡាត់ពោធិកម យូរ-ប៉ុណ្ណ ភណ្ឌុតិណ្ឌុកជាតក (តមកនិងចប់)..... ៤៩០
ព្រះអាចារ្យ ប៉ាង-ខាត់.... អរិយសច្ចជាពុទ្ធភាសិត (តមក)..... ៥០១

---

ឆ្នាំទី ១៧ លេខ ៩ ខែសេបតេមប្រ៍ ១៩៤៥ - ដំឡៃជាវ: ១ ឆ្នាំ ១៥ រៀល ។

# រឿងសុមនមាលាការ

កព្យកាព្យ ៣

## អ្នកឧកញ៉ាភក្តីសារទេព កែ-ឆេត រៀបរៀង

ព្រះមហាឡុច និងមហា ទិទ-ហ៊ួត ក្រុមជំនុំព្រះត្រៃបិដក

នៅពុទ្ធសាសនបណ្ឌិត្យ ជាអ្នកជួយពិនិត្យផ្ទៀងផ្ទាត់

## ពាក្យនមស្ការ

ខ្ញុំសូមលើកការថ្វាយបង្គំ ចំពោះព្រះបរមសាស្ដា ទ្រង់គុណបរិសុទ្ធ ផុតលោកា ករុណាដល់សត្វក្នុងលោកត្រៃ ៗ ក្រមទាំងព្រះធម៌ប្រាំបីហ្មឺន បួនពាន់ខន្ធច្រើនប្រសើរក្រៃ ទ្រង់ប្រោសប្រទានជាកម្រៃ ឲ្យសត្វសព្វថ្ងៃប្រតិបត្តិយក ៗ ព្យាយាមសូត្ររៀនតាមបញ្ញត្តិ នឹងបានផ្ចង់កាត់ព្រះលោក គឺសង្សារវដ្ដកេចដែក កើតមករងទុក្ខវេទនា ៗ ព្រោះតែមោហៈមកបិទបាំង រាំងបញ្ញាឃើញត្រង់គ្នា ទាល់អន្លង់ណាស់ច្រើនគ្រា ស្លាប់កើតគណនាពុំបាន ៗ ព្រមទាំងសាវ័កព្រះមានបុណ្យ ប្រកបដោយគុណឥតប្រមាណ ផ្ដាច់អកុសល ក្ដីសន្ដាន កើតសុខក្សេមក្សាន្ត ដោយបញ្ញា ៗ លោកភាគ្រប់បុណ្យវៃសព្វសត្វ ឲ្យប្រតិបត្តិតាមសាសនា កំចាត់ការអស់ក្ដី ឲ្យស្គាល់ព្រះស្រស់ជ្រះផង ៗ សព្រេច និព្វានផុតអស់ទុក្ខ ដែលកើតទៅមុខអស់បំណង បំណែកអប្សរលង មកត្រង់ ដាច់ខ្លួនដូចគ្រឿងនោះឯង ៗ បង់នមស្ការតែប៉ុណ្ណោះ

ឈប់ស្ទះមិនបានពិស្តារវែង  បន្ទាប់ពីនេះសូមសំដែង  តាំងដើមរឿង សុមនមាលា ។ នាយជាងក្រងផ្កាម្ទះថ្វាយស្ដេច  រំលេចក្បូរក្បាច់សឹងថ្ងៃថ្លា  ថ្វាយពិម្ពិសារាជា  កដ្រើះមហោឡារថ្ងៃ ។ វេលាព្រឹកព្រាងទៀតកាលណា  បែនាផ្កាម្ទះតែសព្វថ្ងៃ  នាំយកទៅថ្វាយគ្មានសល់ ដើម្បីកៃម្រែបិញ្ចឹមប្រាណ ។ ស្ដេចទ្រង់ប្រទានគ្រឿងរង្វាន់  គ្រប់គ្រាន់ប្រាប់ចិតហាប័ណ្ណបាន  ជាងផ្កាទទួលស្រែចរិលប្ពាន  ដល់គេហដ្ឋានឲ្យភរិយា ។ យកទៅទិញដូរគ្រឿងបរិភោគ  តាមធម្មតាលោកសព្វវេលាគ្រាន់តែចិញ្ចឹមអស់គ្នា  គឺបុត្តភរិយា ញាតិសន្តាន ។

ពេលព្រឹកថ្ងៃមួយព្រះសាស្ដា  មានពួកសាវកៈច្រើនប្រមាណ ហែហមចោមរោមចរចេញភ្លាម  ចាកពីវត្តហានទ្រង់បិណ្ឌបាត ។ អ្នកក្រងផ្កាត្រេកអរយ៉ាងពន់  ផ្អើលឆោឡោលាន់រត់ព្រោងព្រាត  នាំយកបង្ហាន់ទៅដាក់បាត្រ  តាមមាគ៌ាស្អាតល្អថ្ងៃថ្លា ។ ព្រះសម្ពុទ្ធស្ដេចទ្រង់គោចរ  រុងរឿងបវរដោយរស្មី  ប្រោសសត្វឲ្យបានរួចទុក្ខ  ដោយមហាករុណាប្រសើរក្រៃ ។ គ្រានោះសុមនមាលា  កាន់ផ្កាម្ទះជាប់នៅដៃ  ដើរទៅដល់អង្គព្រះចមក្រៃ  កើតក្ដីពិសម័យក្នុងចិន្តា ។ ឃើញឆព្វណ្ណព្រះសម្ពុទ្ធ  រស្មីភ្លឺផុតលើសលោកា  ចេញពីព្រះកាយរុងរឿងថ្លា  កើតសោមនស្សត្រេកអរក្រៃ ។ គិតថាពេលនេះមានលាភធំ  ប្រសើរឧត្តមជាងសព្វថ្ងៃ  បានជួបព្រះពុទ្ធសិរីប្រពៃ  វិសេសថ្លាថ្លៃ

រកប្រៀបគ្មាន ។ ឥឡូវអញចេញនាំគ្នាមុំ ហើយនាំផ្កាឈូកថ្វាយពាន
បូជាដល់គន្ធព្រះទ្រង់ញាណ នឹងបានគាប់សព្វប្រែនកល្យា ។ ផ្កានេះ
សម្រាប់ទុកថ្វាយស្ដេច មិនដែលការវេះចេញពាក្យ តែងយកទៅថ្វាយ
សព្វវេលា គន្ធដ៏មួយគ្រាខុសបញ្ញត្តិ ។ មានទោសជាប់គុកជាប់
ច្រវាក់ ពេជ្ឈឃាតកយកាក់នាំទៅកាត់ ដៃជើងបបួនប្រាំកំណាត់
ព្រោះតែបំបាក់ព្រះអាជ្ញា ។ វេលានេះគួរអញលះបង់ ជីវិតក៏ចង់សេ
ដល់ណា យកផ្កាទៅថ្វាយព្រះសាស្ដា នឹងបានផលាអានិសង្សថ្វាយ ។
ទោះស្ដេចក្រុងថានឹងធ្វើទោស ឬអ្នកទ្រង់ប្រោសគង់ព្រួសសាយ ព្រោះ
មានសទ្ធាមិនកែងកាយ ពុំស្ដាយជីវិតនឹងបុណ្យពាន ។ ថ្វាយស្ដេច
បានត្រឹមតែរង្វាន់ ចប់ទល់មិនទាន់សេចក្ដីឃ្លាន បើអញថ្វាយដល់
ព្រះទ្រង់ញាណ នឹងមានផលប្រែនឥតឧបមា ។ ប្រែនជាតិក្រៃន
ជាន់ស៊ីងខ្ពង់ខ្ពស់ តាមព្រះទ្រង់ប្រោសត្រាស់ទេសនា ជាជនធ្វើពាន
ចិត្តក្រៀវក្រា តែងបានផលាកេរប្រៀបគ្មាន ។ គិតស្រេចកាន់ផ្កាដើរ
ចូលទៅ ថ្វាយនៅទៀបបាទព្រះទ្រង់ញាណ ហើយតាំងប្រាថ្នាអធិដ្ឋាន
ឲ្យបានផ្កានោះហែព្រះអង្គ ។ ផ្កាពីរក្រែងជាពិភាន ពីរក្រែងបាន
បាំងក្រោយទ្រង់ ពីរទៀតអាងស្ពាំបាំងឈរត្រង់ ខាងជើងព្រះអង្គ
ពីរក្រែង ។ ព្រះពុទ្ធទ្រង់យាងតាមមាគ៌ា ផ្កាល្អមហិមាហែត្រ-
សង ដូចជាមានមនុស្សតាមក្រោង អស្ចារ្យក្នុងគ្រានោះឯង ។

ហាក់ដូចនាំនិច្ចាំងព្រះអង្គ ក្រអូបក្លិនឆ្ងន់សាយត្រូវស្រួល ពួកជនប្រុស
ស្រីច្រើនក្រៃលែង សឹងតែគោរពព្រះសាស្តា ៗ លាន់ឮគឹកកង
ព្រះធរណី អស្ចារ្យពេញទីខាំងណាស់ណោ សរសើរបារមីគ្រប់ពពា ផ្អើល
ដល់ទេវតាទាំងតាវត្រៃ ៗ ថ្វាយសាធុការគគ្រឹកគេង ឮត្រៃកន្ទ្រឹងក្នុងក្រុង
ត្រៃ ខ្លះកាន់ផ្តិលបាយដាប់ទៅដៃ គាន់កាន់វៃពៃមើលព្រះអង្គ ៗ សឹងតែ
សរសើរព្រះសាស្តា មិនដែលឃើញផ្កាដ៏ផូរផង់ ពោរពេញជុំជិតខាង
ព្រះអង្គ ឈរមើលហាក់សព្វទិសទី ។ ព្រះពុទ្ធប្រែង ឃើញឧបនិស្ស័យ
ធម្មកំ . មយ.ដា ... នាយមាលាការ ... ប្រការពេញចិត្តជ្រះ
ជ្រះថ្លា ៗ ពៃរចគិតត្រង់ការស្លាប់ទីងរស់ ចង់បានជាន់ខ្ពស់បូជាផ្កា
កម្រមានរូបបុគ្គលណា ដូចជាក្រងផ្កាម្ទះនេះឯង ។ នាយសុមនមាលា-
ការ ឃើញហេតុអស្ចារ្យប្រាកដស្តែង រីករាយសោមនស្សក្រៃលើស
លែង រិលទៅទាំងប្រាប់ភរិយា ៗ ដល់ហើយទើបថ្លែងសរសើរ
គុណ នៃបុណ្យដែលបានបូជាផ្កា ចំពោះរស់អង្គព្រះសាស្តា ឃើញ
ជាថ្លៃកវិទ្ធិលើសលប់ក្រៃ ៗ លឿនលយបាំងអង្គព្រះជមកត តាម
គ្រប់ដំហានវិសេសថ្លៃ ផ្កានោះហាក់ដូចទាំងដូនថៃ បងត្រែកអរក្រៃ
កន្លង ៗ ថ្ងៃនេះបងនាំយកទៅថ្វាយ មហាក្សត្រពណ្ណកាយ
លើសិរសា ទទួលទុក្ខទោសព្រះអាជ្ញា ទ្រង់ជួយរាំងណាតាមព្រះ
ទ័យ ។ ស្រេចហើយទីនបុណ្យដ៏ខ្ពង់ខ្ពស់ ទោះបីស្លាប់រស់បងមិនភ័យ

ផ្សេងតាមសំណាងហេតុបច្ច័យ ក្បួនក្បាលជីវិតមិនគិតស្តាយ ។ ព្រោះ-
កើតមកនេះត្រូវបានជួប ព្រះពុទ្ធតែប៉ុន្មានមនុស្សទាំងឡាយ បើបានជួប
ហើយត្រូវតែថ្វាយ ទានផលកុំស្តាយខ្លួនសោះ ។ ភរិយាស្តាប់ហើយទឹងព្រ-
ឡោត ហោះហៅត្រូវក្រោធថាឱប៉ី អ្នកឯងមិនដឹងខេត្តអ្វីនេះ អំណាច
ខ្ញុំនៅក្រពងអាថ៌ ។ អ្នកណាគម្រោងពីជបញ្ញត្តិ ស្តេចយកទៅតាត
ដោតសិរសា ទុកជាចម្រាមពេស្ត្រប្រជា ប្រសស្រីនានាកុំប៊ីត្រាប់ ។
អ្នកឯងហៅពេញជាចង្រៃ បញ្ញត្តិសត្វថ្វីមិនព្រមស្តាប់ ចរចសមុទ្ររង់
គង់ទឹងស្លាប់ ខ្ញុំប្រាប់ឲ្យ ឯងដឹងសេចក្តី ។ ចាប់តាំងអំពីពេលនេះឯង
ខ្ញុំលែងយកអ្នកធ្វើជាប្តី ព្រោះអ្នកជាមនុស្សកាចឫកណ្ហី គស់ត្រូវការអ្វី
ទាំងអស់ហើយ ។ ជាស្រាករៀបខ្លួនដើរចេញទៅ ទូលព្រះចម្រៅម្ចាស់
ត្រាណត្រើយ តាមរឿងខ្លួនឯងមិនមានស្បើយ ឥតគិតអ្វីឡើយពី
ស្លាប់រស់ ។ ទូលថាបពិត្រព្រះទរបតី ទ្រង់គុណធ្ងារម៉ែព្រះកិត្តិយស
ស្វាមីខ្ញុំម្ចាស់ឥតសប្បុរស មិនដឹងទាបខ្ពស់កិច្ចនានា ។ ហ៊ានយកផ្កា
ម្លិះជាផ្កាយ សម្រាប់ទុកថ្វាយព្រះពាង ទៅថ្វាយដល់អង្គព្រះសាស្តា
ផ្ទះថ្វាមិនគិតស្តាយជីវិត ។ ឥឡូវខ្ញុំម្ចាស់ខឹងស្វាមី លែងរួមមេត្រី
ត្រេកស្នាលសនិទ្ធ ពីថ្ងៃនេះទៅជាកំរិត សូមមហាបពិត្រកុំគន្លា ។
ព្រះករុណាពាក់ម្ចាស់នៃផែនដី កុំត្រាប្រណីដោយមេត្តា ធ្វើទោសសុម-
នមាលា ឲ្យបានវេទនាបាក់គេរលោះ ។ ឯខ្ញុំម្ចាស់មិនយកអត

រួមចូលគំនិតនឹងគាត់នោះ ព្រះអង្គកុំទ្រង់អនុគ្រោះ ធ្វើទោសចំពោះប្ដីនោះឯង ។ គ្រានោះសម្ដេចព្រះបរមពង្ស ស្ដេចទ្រង់ព្រះយល់ញច្បាស់ថ្លែង ថាមេទេះចិត្តអាក្រក់ស្ដែង មិនស្វែងរកគុណប្រសើរសោះ ។ ស្រីនេះយ៉ាប់ពេញកាឡកណ្ណី ហ៊ានពោលសំដីប្រឡោះឡោះ បង្ខំប្ដីឯងឲ្យកាប់ឈ្មោះ ចាត់ស្បូវកេះដោយមុសា ។ ស្វាមីផងខ្លួន ។ ប្រមាថ ៖ មើលងាយហួសខ្នាតខុសគម្រោ មិនមានករុណាតប្ដីឡើយណា ដោះសាយករូបតែខ្លួនឯង ។ កាលគ្រាប្ដីមានសម្បត្តិពិត ត្រេកអរលោកចិត្តប្រែបែរវែង ដល់ប្ដីមានទុក្ខទោសគិតលែង យកសុខតែឯងឲ្យប្ដីស្លាប់ ។ គ្រានោះព្រះបាទពិម្ពិសារ ស្ដេចធ្វើជាខ្ញាល់ហើយសារសព្ទទ្រង់ព្រះត្រាស់ជាប្រញាប់ តាមច្បាប់ដល់សុមនមាលា ។ ចិត្តពុំមិនខ្លាចកងបម្រាម ដែលយើងបានហាមពីរឿងផ្កា ហ៊ានយកទៅថ្វាយព្រះសាស្ដា មិនខ្លាចអាជ្ញាព្រះមហាក្សត្រ ។ នាងឯងឈប់សិនកុំអាលលែងពាំ យើងចាត់ចែងដោយសម្ងាត់ ពិនិត្យស្បូវសិនសមអាវគាត់ ក្រែងប្ដីគេចាត់នាងខ្លាសគេ ។ នាងនោះក្រឡប់ក្រាបទូលយោត ថាខ្ញុំមិនយកគាត់នោះទេ ព្រោះប្ដីនោះមុកមិនដូចគេ សូមទ្រង់ព្រះពិចារណា ។ ទូលស្រេចក្រាបថ្វាយបង្គំ៖ ចំពោះទៅផ្ទះនៃគ្នា នាំកកូនទៅចេញយាត្រា គ្មានចិត្តមេត្តាដល់ស្វាមី ។ ទៅនៅសំណាក់ខ្លួនញាតិ ធ្វើឬកមារ-យាទប្រើប្រែប្រួយ មិនឲ្យជនណាដឹងសេចក្ដី គេសង្ស័យប្រណីដោយ

មេត្តា ។ ចំណែកខាងអគ្គព្រះពុទ្ធ មានញាណមុះមុតដូចពេជ្រថ្ង
ទ្រង់បានទទួលកម្រងផ្កា ស្រែបស្ដេចយាត្រាត្រឡប់ទៅ ។ ឯផ្ការនាំង
បាំងព្រះអង្គ ក្រមួចក្តិនធ្ងន់តាមជាប់នៅ ព្រះសង្ឃសាវកហែខ្វល់ខ្វា
ភ្លោះទៅកាំងស្ដេចពិម្ពិសារពេជ ។ ដើម្បីទីងផ្ញើកិច្ចកត្តា ឲ្យស្ដេចជ្រះថ្លា
ពេញអំណាច ថ្វាយទានឥតមានព្រះទ័យខ្លាច អង់អាចស្មោះត្រង់ដោយ
ករពិត ។ គ្រានោះមហាជនសឹងខ្វាបកោក ដៃសោកកាន់ទន់ហែ
ដុំជិត ច្រើនណែនគាន់គាប់ខ្ញាំងនឹក ដោយវិទ្ធបារមីព្រះសាស្ដា ។
នាំគ្នាស្រែកហោកោលាហល រំពងឮដល់ព្រះភជា ទ្រង់ទីងពិភាល់
ធ្លល់ណាសំណា ត្រាស់ប្រើអមាត្យឲ្យទៅមើល ។ ថាឯងប្រញាប់
ឆាប់មិនា កុំដើរយេកផ្ទង់ងើល អាមាត្យបង្គំគេជដើល ទៅមើលឃើញ
អគ្គព្រះជិនស្រី ។ មានសាវកច្រើនពាល់ដាប់ ណាសំណាន់កាន់
គាប់ដោយបារមី ត្រឡប់មកទូលព្រះនរបតី ថាព្រះជិនស្រីទីងសាវក ។
ទ្រង់ស្ដេចមកប្រោសជនប្រុសស្រី ដោយក្ដីករុណាជាពំនាក់ មហាក្សត្រ
ទ្រង់ជ្រាបប្រាកដជាក់ ព្រះទ័យស្មោះសុំត្រេកអរឧបមា ។ ទើបទ្រង់
ឲ្យចាត់កត្តុយោងឯក ល្អៃបុកមានរសឈ្ងាញពិសា នាំយកទៅថ្វាយព្រះ
សាស្ដា ទីងសាវកមុខព្រះភេទ ។ ឯអស់ពួកស្រីសុំកញ្ញា រូប
ឆោតឆាយស្រស់កល្យាណ ទីងពួកខាហ៊ានតាំងបុទ្ទាន គាត់តែងខ្លួន
ប្រាណហែព្រះអង្គ ។ ដល់មុខព្រះលានឃើញព្រះពុទ្ធ ទនអង្គលំគ

ផ្កាតម្រង់ គ្រឹនផ្កាក្រមួនប៉ះមកត្រង់ ព្រះទ័យដ៏រុងរឿងផ្ទះភ្នា ។ ពិតផលពុទ្ធគុណាជាអនេក យញ្ញាស្មូត្រប្រែក និងចម្ការ សរសើរ បារមីព្រះសាស្តា ថាកេខណោប្រៀបពុំបាន ។ ទើបស្តេចលើក គ្រឿងកត្តាហារ នឹងរកសរបរិក្ខារទាំងប៉ុន្មាន ថ្វាយផលស ម្តចព្រះ ទ្រង់ញាណ ទីកសាវកបានត្រាំទាំងអស់ ។ ព្រះអង្គទទួលបិណ្ឌ- បាតស្រេច សម្រេចភត្តកិច្ចព្រះទ្រង់យស សំដែងអំពីអម្រឹតរស ជាធម៌ជាទីខ្ពស់ត្រាសពជា ។ លុះអនុមោទនារួចហើយស្រេច ព្រះ សព្វេជ្ញថ្វាយព្រះពរលា ត្រឡប់ចាកក្រុងរាជការ ទៅគង់នៅនាគន្ធ- កុដិ ។ រីឯផ្កាម្រះសត្រសុស ដែលចុះជោរជាសំណាថែនជ័ រ៉ក្សស៊ីមក្ការ វត្តព្រះជិនស្រី មើលទៅគយល់ត្រជាក់ថ្លា ។ ព្រះបាទធម្មសារវិសេស សុទ្ធ ដន្លែព្រះពុទ្ធស្រេចកាលណា ស្តេចថ្វាយបង្គំព្រះសាស្តា ទ្រង់លា វិលទៅប្រាសាទថ្លៃ ។ ទើបត្រាស់ឲ្យហៅនាយមាលា ជាជាងក្រង ផ្កាថ្វាយសព្វថ្ងៃ ឲ្យចូលមកគាល់ព្រះភូវនៃយ ក្សត្រិថ្លៃទើបមានបន្ទូល ថា ។ នែរ៉ូយអ្នកជាងផ្កាម្រេង យើងអរកន្ធុនឥតឧបមា ចំពោះគុណ អ្នកពីថ្ងៃថា កម្រនណានឹងធ្វើបាន ។ អ្នកឯងបរះជឿគុណព្រះពុទ្ធ សើបស្មូនមុះមុតក់ងសិន្ទានទ នេះហៅថាមើព្រះណិបាន គឺសុខក្សេម ក្សាន្តគិតញ្ញាន ។ យើងឲ្យរង្វាន់តបគុណអ្នក ព្រោះបានជឿជាក់ ថ្វាយផ្កាទាន ដល់អង្គសម្តេចព្រះទ្រង់ញាណ ឥតមានខណោះធ្វើ

ដូចអ្នក ៗ យើងទាំងប្រមាណទ្រព្យរបស់ ដោយចិត្តសប្បុរសចិន ទីសពាក់
សេះទឹងដំរីតាំងទ្រមាក់ សំដីកែបំពាក់គ្រឿងនានា ៗ មានទាំងខ្ញុំប្រុស
នឹងខ្ញុំស្រី សុទ្ធតែប្រាំបីសេះ ១ គ្នា តាមពិតដូចយើងបានពណ៌នា ទាំង
ស្រីសោភាប្រាំបីនាក់ ៗ ទំរង់គ្រឿងប្រដាប់សម្រាប់តែង មាសពេជ្រ
បរិស្ការគ្រឿងស្លៀកពាក់ ឃើញឲ្យដោយចិត្តដ៏ស្មោះស្ម័គ្រ ព្រោះអ្នក
វិសេសប្រសើរពេក ៗ ប្រមាណទាំងផ្ទះ ៨ ខ្នង ធំហើយល្អផងខ្ពស់ត្រ-
ឈៃ ប្រាំបីពាន់ប្រាក់ជាកម្រៃ ទំរង់គ្រឿងដាំឡែឥតមានខ្ចោះ ៗ ហើយ
ទ្រង់ចង្អាប់ផុទ្រក្រសួង ឲ្យនាំគ្រឿងហូងមកទៀតខ្លះ ប្រមាណព្រះទ័យ
ផុតស្រឡះ បានព្រះកំណាញ់ជាប្រធាន ៗ ស្រេចហើយរើបនាយ
កម្រងផ្កា បង្គំក្រាបលាថយចេញមាន ស្រីស្រស់រូបល្អស្អេចប្រមាណ
វៃហាងដល់ឋានទេពគ្រឹហា ៗ ទើបរៀបចាត់ចែងផ្ទះប្រាំបី ឲ្យកំលោះថ្មី
នៅផ្សេងគ្នា ដើម្បីកុំឲ្យគេនិន្ទា លមតាមវេលាជាប្រក្រតី ៗ គ្រានោះ
អានន្ទមានគំនិត បានចូលទៅជិតព្រះជិនស្រី បង្គំទូលសួររឿងសេចក្ដី
ការបូជាថ្វៃទានផ្កា ៗ ដែលបានថ្វាយដល់ព្រះសម្ពុទ្ធ ទ្រង់គុណវិសុទ្ធ
ដ៏ថ្លៃថ្លា តើទាននោះមានផលយ៉ាងណា សូមទ្រង់មេត្តាប្រាសសំដែង ៗ
រីអង្គសម្ដេចព្រះភគវា ទទួលអារាធនាពេលនោះឯង ត្រាស់ដោយព្រះ
ញាណឃើញច្បាស់ចែង ទើបទ្រង់សំដែងប្រមាណប្រាប់ ៗ ថានែអា-
នន្ទអនុជអគ្គ ចូរគ្រងឲ្យដាក់ចិត្តចាំស្ដាប់ នាយជាងក្រងផ្កាដែលបូរ

ស្លាប់ ផលជូនធុតធាប់ដូចប្រាថ្នា ៗ ព្រោះមានសទ្ធាខ្ជាប់លើសលន់
លើសលុបពេកពន់ឥតឧបមា បានយកចង្កោមកម្រងផ្កា បូជាតថាគត
នេះឯង ៗ ផលនេះវិសេសវិសាលណាស់ ប្រាកដជាកប្រាស់ជួយ
គាត់តែង ឲ្យបានទ្រព្យធនធំចាំក្លាង បញ្ចប់គួរស្មើស្ងប់គ្រប់គ្នា ៗ
បុគ្គលនេះបានទៅកើត ឋានយកកំណើតជាទេព សោយសុខមិន
គាប់ទីធនណា អស់កាលវេលាអន្លង់ឆ្ងាយ ៗ អន្ទោលចុះឡើងក្នុង
ត្រកូល កុសលជួយទប់ទល់រូបកាយ មិនឲ្យធ្លាក់ទៅក្នុងអបាយ ផុត
ពីអន្តរាយមួយសែនកប្ប ៗ លុះដល់ទៅជាតិទីបំផុត បានជាបច្ចេក-
ពុទ្ធសិទ្ធផុតផាប់ ត្រាស់ដឹងធម៌អាចយាំងចំណាប់ តថាគតប្រាប់ដូច្នេះ
ឯង ៗ ទ្រង់នាមជាព្រះសុមនៈ ផ្ដះអស់កតៈគ្រឿងចំបែង អវិជ្ជា
ឫសគល់នាំគាត់តែង ស្រឡះបាត់ផ្សេងចូលទិញ្ញាន ៗ ជនណាឧស្សាហ៍
សាងកុសល ចំរើនភ្ញាយខ្វល់កេសីលទាន ការនោះមិនអាចឲ្យកើតមាន
ជននោះនឹងបានឋានសុគតិ ៗ កុំឲ្យគ្រាក់គ្រេងមិត្តជាន នរកប្រែត
សាមានឲ្យមកជាមិត្ត គ្រសារគ្រោបទុក្ខរូបរឹត នឹងគន់ដល់ដល់ខ្លួន
ប្រាណ ៗ ធម៌ណាអាក្រក់ព្រះលោកប្រាប់ គួរតែយើងស្ដាប់តាំឲ្យបាន
ដូចជាវេកតាំង ៥ ឋាន ព្រះអង្គលោកបានហាមគ្រប់គ្នា ៗ ទី ១ បាណា-
តិបាតា កុំឲ្យប្រាថ្នាផ្ដាច់ជន្មា ជីវិតមនុស្សសត្វផងនានា ដោយចិត្ត
កាលាមិនគិតខ្លាច ៗ ហាមតាំងពីពន្យមានពាក្យ កុំឲ្យស្មោរកាត់តាំងអំណាច

ផ្តាច់ពួកសត្វតូចតាច ជាដើមរហូតតាបវៀរឲ្យបាន ។ ទី ២ ហាម ផ្តាច់គំនិតខ្លួច យ៉ាងហោចណាស់អទិន្នាទាន កុំឲ្យលួចប្លន់ដើររកកន ឆបោក ផនជានជនទាន់ ។ ទី ៣ កាមេសុមិច្ឆា កុំឲ្យប្រាថ្នាបុត្រភរិយា របស់ គេដែលថែសព្វវេលា ទោសធ្ងន់មហាមាំក្រៃកន្លង ។ ទី ៤ អំពីមុសាវាទ កុំរាលលៀងឃ្លាតខុសទំនង កុហកបញ្ឆោតគេម្តងៗ នាំឲ្យសៅហ្មង ពន់ប្រមាណ ។ ទី ៥ សុរាមេរយៈ ត្រូវជាក់ផុតចេញកុំរាន កុំយក មកផឹកថាស្រួលប្រាណ ស្រួលបានតែបាបប៉ុណ្ណោះឯង ។ ទោសផឹក សុរាធ្ងន់ពេកណាស់ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែង ពួកអ្នកប្រមឹកគួរ វៀរវេរង ញរៈញីគរគោតក្រែងភ្លើងអវីចី ។ សីលទាំង ៥ ដូចបានថ្លែង ស្តាប់ឮជាក់ស្តែងទាំងប្រុសស្រី ត្រូវលះបោលចេញកុំស្តាយថ្វី នាំគា- ឲ្យកណ្តាបាបដល់ខ្លួន ។ ពីនេះសំដែងរឿងសច្ចៈ រៀងជារយៈតាមចំនួន លោកបានពោលទុកថាមាន ៤ តាមក្បួនច្បាប់ពុទ្ធសាសនា ។ សច្ចៈទី ១ បានតាងទុក្ខ តែងតាមលុយលុកពលរូបា តាំងពីនៅក្នុងផ្ទៃមាតា ឥត មានទីរវារពេះគេចបាន ។ វេលាប្រសូតចេញមកទៀត ទុក្ខតាម បៀតបៀនគ្មានស្រាកស្រាន្ត រហូតទៅដល់ពេលបែកប្រាណ ទុក្ខខ្លាំងប្រ- មាណឥតឧបមា ។ ទុក្ខសច្ចលោកចាត់ចាំជាផល គួរគិតឲ្យដល់កុំកន្លា ឲ្យឃើញជាក់ច្បាស់ដោយបញ្ញា ដូចអង្គសាស្តាទ្រង់សំដែង ។ សច្ចៈ ទី ២ នោះដោយឡែក ព្រះពុទ្ធទ្រង់បែកតាមតំណែង បានតាំងតណ្ហា

នាំតាក់តែង ទុក្ខយូរអង្វែងវៀនកល់ជាតិ ។ តណ្ហាជាហេតុជាប្រមុខ ដឹកនាំក្នុងទុក្ខមិនកេត មិនឆាយសព្វសត្វទាំងបានឃ្លាត លុះតែផុតជាតិទើបទុក្ខគ្មាន ។ សច្ចៈទី ៣ បាននាងហាន សុខស្រួលក្សេមក្សាន្តគឺនិព្វាន រំលត់គ្រឿងទុក្ខមិនឲ្យមាន ដូចបាននិកានប្រាប់ក្តួល ។ និរោធសច្ចនេះឯងណា ពោលតាមពុទ្ធដីកាថាជាផល ព្រោះកើតអំពីបុណ្យកុសល តែងជួយដំកល់ដំកើងសត្វ ។ សច្ចៈទី ៤ បាននាងមគ្គ ជាផ្លូវឯកអគ្គប្រសើរក្តាត់ សម្រាប់ពួកជនអ្នកប្រតិបត្តិ ដើរកាត់ទៅកាន់អម្រឹតបុរី ។ ផ្លូវនេះប្រាកដជាផ្លូវត្រង់ បើចែកតាមអង្គមានប្រាំបី អស់ពួកសប្បុរសទាំងប្រុសស្រី ធ្លាប់ជ្រាបសេចក្តីខ្លះទៅហើយ ។ ផ្លូវនេះសម្រាប់ជនប្រសើរ តែងធ្វើដំណើរទៅកាន់ត្រើយ និព្វានរំលត់ទុក្ខសះស្បើយ ហានហឹងឯងហើយផុតកង្វល់ ។ មគ្គសច្ចៈនេះជាហេតុ នាំសត្វអណ្តែតឡើងទៅដល់ នាទីខ្ពង់ខ្ពស់គឺមគ្គផល ផ្តាច់អកុសលកងសង្សារ ។

និទានអំពីនាយមាលា ទីងបទរេវពប្រាំប្រការ សព្វគុម្ពីបួនមានខ្លឹមសារ ពុំបានពិស្តារទូលាយវែង ។ រៀបរៀងរឿងនេះមិនបានសព្វសូមស្មុះបញ្ចប់ប៉ុណ្ណោះឯង បន្ទាប់ពីនេះទីងសូមថ្លែង នាមខ្ញុំអ្នកតែងនិងការខ្លួន ។ ខ្ញុំឈ្មោះកែ-នេតតែងរួលបេញ នៅក្រុងភ្នំពេញឃុំលេខ ៤ បានធ្វើជការពេញសំនួន យសសម្រាប់ខ្លួនទាងលិខិត ។ ការការខ្ញុំនោះជាកជាទី ១ កញ្ញាកក្តីសារ៖ទពពិត ព្រះករុណាជាម្ចាស់ថ្លៃជីវិត

ស្ដេចក្រង់មានបុត្តិប្រមាណគ្យ ៗ ខ្ញុំរៀបរៀងតែងសេចក្ដី ប្រយោជន៍ ដើម្បីជនខាងក្រោយ ត្រាន់បានអានមើលដឹងជ្រះជ្រាយ កុំឲ្យធ្វេះ ធ្លោយការប្រតិបត្តិ ៗ រៀបរាប់ពីរឿងតាមអាការ តាមដោយវោហារ ដែលបានចាំ តែងទុកការពារប្រុងប្រយ័ត្ន បើរូបទៅបាត់ឈ្មោះ ខ្ញុំនៅ ៗ

ចប់

# សេចក្ដីសង្ខេបអំពីគោលផ្សេងៗ នៃពង្សាវតារខ្មែរ

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

រៀបរៀង (តបក)

ប្រវត្តិពង្សាវតារនេះ ចាប់តាំងពីព្រះបាទទេវង្សអស្ចារ្យ រហូតមកដល់គ្រាស្រក់ថ្នម ដែលសម្ដេចព្រះសុគន្ធបានរៀបរៀងទុកមកហើយ ប្រែទតែប្រែសកកពជបុកណាផង ទីធំរឿងក៏វែលកន្លងមកអាន្ទឹនហើយ អ្នកស្រុកពេះចាំតៗគ្នាមក ប៉ុន្តែសេចក្ដីរៀបរៀងនេះមិនពិស្ដារទេ ។ ទើបព្រះអង្គម្ចាស់ទ្រង់គិតថា គួរតែធ្វើព្រះរាជពង្សាវតារឲ្យបានពិស្ដារ ដើម្បីឲ្យអ្នកស្រុកបានចេះដឹងពល់គ្នា ទើបទ្រង់រៀបរៀងតាមរឿងរ៉ាវដូចមានតទៅនេះ ។ សេចក្ដីតែងជាន់ចាស់ (របស់ព្រះសុគន្ធ) មានតែបញ្ជីកយ៉ោះ ដែលបានស្រង់យកមកពីរឿងរ៉ាវផ្សេងៗ ខាងក្រោមនេះ៖

ព្រះពុទ្ធទំនាយ និងជួសម័យរបស់ព្រះបាទទេវង្សអស្ចារ្យមាននៅក្នុងក្បួនពុទ្ធទំនាយ ។

តាំងពីព្រះកេតុមាលាមកដល់ព្រះបទុមវង្ស មាននៅក្នុងពង្សាវតាររបស់ពួកបាគូ ។

វគ្គកាលព្រះធម្មិកជនីងពីព្រះពុមស្សរវង្ស មានរឿងក៏ពិស្ដារក្នុងពង្សាវតារសៀមថែកខាងជ័យទិនទំនាយព្រះកែវ ។

តាំងពីព្រះបាទធ្មេញជ្រៀកមកដល់ព្រះបាទសេនករាជ និងព្រះបាទសិង្ហកុមារ មានសេចក្ដីដំណាលក្នុងគម្ពីររតនពិម្ពវង្ស ។

តាំងពីព្រះបាទសន្ធបក្រ, បក្រពង្កកជ, បក្សីចាំក្រុង និងតាត្រសក់ផ្អែម មានសេចក្តីដំណាលក្នុងក្បួនឥសីទំនាយ ។

តាំងពីដំបងក្រញូង, ពញាក្រែក និងបក្សីចាំក្រុង មានដំណាលក្នុងពង្សាវតារលោក និងពង្សាវតារសៀមខាងដើម ។

"សល់ក្រៅអំពីនេះ គេបានចម្លងយកមកពីក្បួនផ្សេងៗ និងសេចក្តីកត់ត្រារបស់អាចារ្យជាន់ចាស់" ។

*

* *

ព្រះរាជពង្សាវតារខ្មែរ ដែលបានសាយភាយនៅក្នុងស្រុកខ្មែរសព្វថ្ងៃនេះ ដោយលោក អាត់-លីក្លេ បានប្រែបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩១៤ ។ នៅប្រែអមលោកនេះ មានក្រុមជំនុំ ១ ក្រុមដែលព្រះបាទសម្តេចព្រះនរោត្តមទ្រង់តាំងឡើង ដោយមានសម្តេចព្រះមហាសង្ឃរាជព្រះនាមទៀងជាអធិបតី ក្រៅពីនេះមានអ្នកធំៗ ដូចជាសម្តេចព្រះសុគន្ធ ប៉ាន និងអ្នកឧកញ៉ាសុទ្ធរពោហារ ម៉ុក កវីឯករបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមជាដើម (ចំពោះសម្តេចព្រះមហាសង្ឃរាជទៀងនោះ ទិវង្គតទៅនៅថ្ងៃ ២ ឧកក្រូប៍ ១៩១៣ ព្រះជន្ម ៩០ វស្សា) ។

ដល់មកក្នុងថ្ងៃ ២៣ មារ្ស ១៩០៣ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទ្រង់មានព្រះបន្ទូលឲ្យតាក់តែងតែងពង្សាវតារជាថ្មីឡើងទៀត

ដោយទ្រង់អានថា សំណៅពង្សាវតារចាស់ៗនោះបាត់បង់ទៅហើយ ឬអន្តរាយបាត់ខ្លះទៅហើយ ។

កាលពីក្នុងឆ្នាំ ១៧៨៦ នោះ ព្រះករុណាព្រះអង្គអេង បានថ្វាយសំណៅពង្សាវតារដល់ស្តេចសៀមព្រះពុទ្ធយ៉តហ្វាចុឡាលោក ។ តទៅនេះជាសេចក្តីប្រែតាមសំណៅដើមនោះឯង:

ក្នុងចុល្លសករាជ ១១៤៨, ឆ្នាំមមីអដ្ឋស័ក (គ.ស. ១៧៨៦) ថ្ងៃព្រហស្បតិ៍ ៧ កើតខែជេស្ឋ ព្រះកមាធិបតី[1] បានថ្វាយព្រះរាជពង្សាវតារនេះ ។ ព្រះករុណាជាម្ចាស់ជីវិត[2] ទ្រង់តាក់តាំងហ្លួងពចនាពិចិត្រ ១ ឃុនសារប្រសើរ ១ ឃុនមហាសិទ្ធិ ១ នាយជំនិតហោរ ១ ឲ្យប្រែព្រះរាជពង្សាវតារនោះជាភាសាសៀម ហើយថែរក្សាទុកក្នុងហោព្រះសមុទហ្លួង ។

ក្នុងសករាជ ១២៦៨[3] ឆ្នាំចអដ្ឋស័ក (គ.ស. ១៣៤៦) សម្តេចព្រះមហានិពាន[4] សោយរាជ្យនៅស្រីយសោធរនគរ ទ្រង់ទំនុកបម្រុងព្រះសាសនា ។ ក្នុងសម័យនោះ សម្តេចព្រះកមាធិបតី ជាព្រះរាជបុត្រសម្តេចព្រះមហាបរមត្តកជាធិរាជ ទ្រង់គ្រងរាជសម្បត្តិនៅអយុធ្យា ។

---

១ កមាធិបតី ជាព្រះនាមមួយរបស់ព្រះករុណាព្រះអង្គអេង ដែលទ្រង់ឡើងរាជាភិសេកតាំងពីឆ្នាំ ១៧៩៤ ហើយទ្រង់ទិវង្គតក្នុងឆ្នាំ ១៧៩៦ ។ ២ ស្តេចសៀមព្រះពុទ្ធយ៉តហ្វាចុឡាលោក ។ ៣ សំណៅដើមមានបន្ថែមចុល្លសករាជ ៧០៨ នៅចន្លោះគ្នាទាំងពីរ ។ ៤ សៀវភៅខ្លះ: មហានិពាន = មហានិព្វាន ។

សម្តេចព្រះមហាធិបតី ទ្រង់ចាត់ព្រាហ្មណ៍ពីររូប[១] ឲ្យនាំព្រះរាជសារ ស្តានមេត្រីទៅក្រុងម្ភា ។ ប៉ុន្តែសម្តេចព្រះមហាទំភូន មិនទ្រង់ជឿជាក់ក្នុងចិត្ត (ក្នុងដំណើរនោះ) ទើបទ្រង់ឲ្យចាប់ព្រាហ្មណ៍ទាំងពីរនាក់សម្លាប់បង់ទៅ ។ ព្រះករុណាស្តេចគ្រងរាជ្យ ៤ ឆ្នាំ ស្តេចទិវង្គតទៅ ។ ទើបពួកក្សត្រាក្សត្រិយ៍ព្រះវង្សានុវង្ស និងពួកសេនា. បតីធ្វើពិធីបូជាព្រះភ្លើងព្រះបរមសពព្រះមហាក្សត្រតាមទំនៀម ។

អ្នកព្រះថៃ ជាព្រះអនុជថ្លៃរបស់ព្រះអង្គ បានឡើងគ្រងរាជសម្បត្តិតមក ។ ក្សត្រិយ៍អង្គនេះទ្រង់សាងព្រះវិហារ, កុដិ, ព្រះពុទ្ធរូបហាសិបពីរព្រះអង្គ ហើយបិទមាសព្រះបដិមាករ ២២ ព្រះអង្គ ។ ទ្រង់ទិវង្គតទៅក្រោយដែលបានគ្រងរាជ្យបានជាវេលា ១០ ឆ្នាំ ។ ព្រះរាជវង្សានុវង្ស និងពួកសេនាបតី ក៏ចាត់ចែងបូជាព្រះភ្លើង ព្រះបរមសពតាមទំនៀម ។

អ្នកព្រះស្រីគុរ ជាព្រះអនុជឡើងគ្រងរាជសម្បត្តិតមក ។ ក្សត្រិយ៍អង្គនេះទ្រង់សាងព្រះវិហារ, កុដិថ្វាយដល់សង្ឃ ប៉ុន្តែវេលាកំពុងកសាងព្រះវិហារនៅឡើយក៏មិនទាន់ហើយស្រេច ស្តេចក៏ទិវង្គតទៅ ក្រោយដែលបានគ្រងរាជ្យមកជាវេលា ៥ ឆ្នាំ ។

លុះបានធ្វើព្រះរាជពិធីបូជាព្រះបរមសពចប់សព្វគ្រប់ហើយ ទើបព្រះរាជនត្តា ព្រះបរមថាខេមរាជា ឡើងគ្រងរាជសម្បត្តិតមក ។ ទ្រង់បានកសាងព្រះវិហារ, កុដិ, ព្រះពុទ្ធរូប ៨ ព្រះអង្គ ហើយទ្រង់ឲ្យប្រមូលរូបរូបពេជ្រ

---

១ កងនៃសេរក៏ · ហៅសែ ហៅបារាំង ។

នឹងគ្រឿងលំអបំពាក់ផ្សេងៗទៀតជាច្រើន មកសម្រាប់ប្រដាប់ព្រះបដិមាករ ។ ព្រះអង្គទិវង្គតទៅក្រោយដែលបានគ្រងរាជ្យមកជាវេលា ៣ វស្សា ។

ក្រោយដែលបានធ្វើព្រះរាជពិធីបូជាព្រះបរមសពរួចហើយ ទើបព្រះអនុជទ្រង់ព្រះនាម សម្ដេចព្រះឡាំពង់បរមរាជាធិរាជឡើងគ្រងរាជ-សម្បត្តិ ។ ព្រះអង្គជាព្រះមហាក្សត្រ ដែលទ្រង់មានវិរិយអំណាចធំ ១ អង្គ ។ ព្រះអង្គគ្រងរាជសម្បត្តិមិនបាន ៤ ឆ្នាំ ទើបសម្ដេចព្រះរាមា-ធិបតីនៃក្រុងអយុធ្យាព្រមដោយព្រះរាជបុត្រ ព្រះបាក្សត្រ, ព្រះបា-សាត់, នឹងព្រះជំបូងពិត លើកកងទ័ពមកច្បាំងនឹងព្រះនគរហ្លួង (ក្រុងអង្គរធំ) ។ ព្រះចៅឡាំពង់រាជាធិរាជ ចេញព្រះរាជប្រកាសកេណ្ឌទ័ពចេញច្បាំង នឹងទប់ទល់យ៉ាងម៉ឺងម៉ាត់ក្លាហាន ។ ដល់ផុត ១ ឆ្នាំទៅ មឿងមិនទាន់សម្រេចយកបានទេ ។ សម្ដេចព្រះឡាំពង់រាជាធិរាជក៏ទិវង្គតទៅ ទើបព្រះអនុជឡើងគ្រងរាជ្យជាតំណតមក ហើយទិវង្គតទៅទៀត ក្រោយដែលបានគ្រងរាជ្យមក ៣ ខែ ។

អ្នកព្រះឡាំពង់ឡើងគ្រងរាជ្យជាលំដាប់តមក ។ ព្រះអង្គទ្រង់ផ្សារភ្ជាប់ទ័ពក្រុង ហើយទប់ទល់ទ្រាំទ្របាន ត្រឹម ១ ខែ ហើយស្ដេចក៏ទិវង្គតទៅក្នុងឆ្នាំនោះ (១) ទើបសម្ដេចព្រះរាមាធិបតីវាយយកបានព្រះ

---

១ ឆ្នាំនោះនៅក្នុងឆ្នាំ ១៣៥២ ឬ ១៣៥៤ ប៉ុន្តែកំណត់ឆ្នាំទាំងពីរនេះ ទុកពិកំណត់ក្នុងសេចក្តីប្រែពង្សាវតារខ្មែរជាន់ក្រោយ ដែលបានកំណត់ក្នុងឆ្នាំ ១៣៥៣ ឆ្នាំឃ្លាញទៅវិញ គិតជារយៈវេលាដល់ ៣០ ឆ្នាំ ក្នុងរវាងពិភពខបទ (១៣៤៦) នឹងការបរាជ័យនៃក្រុងនគរហ្លួង ។

នគរហ្លួន ។ ព្រះអង្គប្រគល់ការត្រួតត្រាព្រះនគរហ្លួនដល់ព្រះរាជបុត្រច្បងព្រះបាក់ក្សត្រ ហើយទ្រង់តាំងព្រះរាជបុត្រពៅនាំងពីរគឺ ប៉ា-អាត់ និងឡាំពង់ពិតជាជំនួយ រួចស្តេចលើកទ័ពតាប់យកពេញ៉យចំនួន ៩០,០០០ នាក់ត្រឡប់ទៅអយុធ្យាវិញ ។

ព្រះចៅបាក់ក្សត្រឡើងសោយរាជសម្បត្តិនគរកម្ពុជា ជាវលា ៣ ឆ្នាំហើយទិវង្គតទៅ ទើបព្រះប៉ា-អាត់ឡើងគ្រងរាជសម្បត្តិ ៣ ឆ្នាំតមកទៀត ក៏ទិវង្គតទៅទៀត ទើបព្រះឡាំពង់ពិតឡើងសោយរាជ្យបាន ៦ ខែទិវង្គតទៅទៀត ។

ទើបអ្នកប្រុក (ព្រែក) ដែលមានងារជាចៅព្រះកលមេឃជាព្រះរាជ-ភាគិនេយ្យ[1] របស់ព្រះបរមរាជាមេភជាឡើងគ្រងរាជសម្បត្តិតមក ។ ព្រះអង្គមានព្រះជេដ្ឋភគិនី ១ ព្រះកនិដ្ឋភគិនី ១ ។ ព្រះនាងច្បងមានព្រះរាជបុត្រ ១ ព្រះអង្គ ព្រះនាមព្រះចៅព្រះឥន្ទ្ររាជា ព្រះនាងពៅមានព្រះរាជបុត្រ ២ អង្គ មួយអង្គព្រះនាម ចៅព្រះគាំខត ១ អង្គទៀតព្រះនាម ចៅព្រះកែវហ្វា ។ ព្រះចៅកលមេឃ ទ្រង់រៀបអភិសេកសមរស ព្រះរាជបុត្រីព្រះនាម នាងសុខទេព្វា ថ្វាយនឹងព្រះភាគិនេយ្យព្រះឥន្ទ្ររាជា ហើយព្រះអង្គលាចេញពីរាជសម្បត្តិ ដោយទ្រង់ប្រោសប្រាណព្រះភាគិនេយ្យនេះ ។ ប៉ុន្តែចៅព្រះគាំខតលួចថ្កើតក្បួយព្រះជន្មទៅ

១ ឬព្រះរាជនត្តា ។

ហើយទទួលយកព្រះនាងសន្ធទិត្រា មកធ្វើជាព្រះជាយារបស់ទ្រង់ ។ ទៅព្រះកលមេឃ ទ្រង់ក្រេវក្រោធនឹងទៅព្រះតាំខតជាខ្លាំង ទ្រង់មិនចង់ឲ្យរាជសម្បត្តិបានទៅទៅព្រះតាំខតទេ ទើបទ្រង់ប្រកាសតាំងយុទរទេព-មន្ត្រីជាស្តេចគ្រងរាជ្យឡើង ។ ស្តេចក្រោយនេះ ស្តេចមកដល់ពាក់កណ្តាលផ្លូវ ទៅព្រះតាំខតតាំងក្បត់ប្រជុំពួកមនុស្សធ្វើគត់ទ្រង់ទៅទៀត ។ អស់ពួកសេនាបតីនាំគ្នាក្រាបទូលអង្វរទៅព្រះកលមេឃឲ្យលះបង់រាជសម្បត្តិថ្វាយទៅព្រះតាំខត ។ ស្តេចក៏ទ្រង់មានព្រះទ័យ [illegible] គ្រងរាជ្យបាន ៣ ឆ្នាំទើបលះរាជសម្បត្តិ ឲ្យទៅព្រះតាំខត ទ្រង់ព្រះនាមជាព្រះកមាធិបតី ។ ចំណែកខាងព្រះនាងសន្ធទិត្រា ក៏បានឡើងជាព្រះអគ្គមហេសី ទ្រង់ព្រះនាម សម្តេចព្រះកកតើប្រីសន្ធទិត្រា ។ ទៅព្រះតាំខតមានព្រះអគ្គមហេសី ១ អង្គទៀត ជាបុត្របស់ចៅមឿងប៉ាង-គាង បានព្រះរាជបុត្រ ២ អង្គ ១ ឈ្មោះព្រះនាមចៅព្រះនាយ៉ក ១ អង្គទៀត ព្រះនាមនាងសន្ធទិត្រា ។ ចៅព្រះតាំខត ជាព្រះមហា-ក្សត្រ ដែលមានអានុភាពច្រើនអង្គ ១ ទ្រង់កាចធ្វើព្រះឧគ្គឲ្យលែងទៅចំណុះក្រុងអយុធ្យា ទើបចៅព្រះតាំខតលើកកងទ័ព ១ ចេញទៅ ដោយទ្រង់ប៉ុនប៉ងនឹងច្បាំងហើយរំលេយកក្រុងអយុធ្យាផង ។ លុះស្តេចលើកទៅដល់ក្រោងសុហុត, ប៉ាង-គាង, ទ្រង់ចាប់បានឈ្លើយជាចំនួនច្រើន ។

ហើយទ្រង់វិលមកដល់ពាក់កណ្ដាលផ្លូវ ។ ស្រាប់តែមេកងក្ដិទ្ធិទ័ពចាម បានប្រជុំគ្នាធ្វើជាកងទ័ពទឹកទូកជាច្រើន ដើម្បីលុកយកមៀងចតុមុខ ។ ពួកខ្មាំងយកបានព្រះពុទ្ធរូបមាសនឹងប្រាក់ ហើយប្រមូលទ័ពបង្គាប់ឲ្យត្រឡប់ទៅច្បាំងនៅគ្រាំងព្រះពេជ្រ ។ ទើបចៅព្រះនាំខត់ស្ដេចត្រឡប់មកព្រះនគរបាទីវិញ ទ្រង់លើកទ័ពចេញទៅច្បាំងនឹងកងទ័ពចាមយ៉ាំងម៉ឺងម៉ាត់ នៅតែមិនអាចយកជ័យជំនះកងទ័ពចាមនឹងកិត្តិបានឡើយ ទើបទ្រង់ទូលអង្វរសូមជ័យជំនះអំពីនាងព្រះធរណី ។ ដល់វេលាត្រី នាងព្រះធរណីមកប្រាកដនៅចំពោះព្រះភក្ត្រព្រះអង្គក្រាបទូលថា "សូមទ្រង់កុំព្រួយព្រះទ័យឡើយ សូមទ្រង់លើកទ័ពទៅច្បាំងនឹងពួកខ្មាំងម្ដងទៀតចុះ ទ្រង់មានជ័យជំនះប្រាកដ" ។ តាំងពីព្រលឹមស្រាងៗ ចៅព្រះតាំងខត់ ក៏លើកទ័ពទៅតតាំងនៅខាងមុខពួកខ្មាំង ។ ព្រះធរណីត្រឡាខ្លួនជាពស់ ១ ល្មូននាំមុខទ្រង់ទៅ ពួកហោរាបានឃើញនិមិត្តដូច្នោះ ក៏នាំគ្នាទាយថា ទ្រង់បានជ័យជំនះ (ពួកខ្មាំង) ។ ចៅព្រះតាំងខត់ស្ដេចឡើងគង់លើព្រះទីនាំងរាជរថផ្ទាលពីពិមាន មានកងទូកពួកមុខមន្ត្រីចោមរោមគោះស្គរជាផ្លូវ ព្រះអង្គទ្រង់សម្រុកច្បាំង ៗ ទូកខ្មាំងឡាយ ក៏ជាប់ច្បាំងគ្នាទៅល្បាបការ ខាងពួកមេកងចាមបានឃើញព្រះចៅតាំងខត់ ទ្រង់មានឫទ្ធានុភាពក៏មានសេចក្ដីភិតភ័យ ខ្លាចកំឡាំងនឹងច្បាំងតតាំងនឹងកងទ័ពហ្វូង ។ ទើបពួកមេទ័ពមេកងរបស់

ព្រះចៅតាំងត ក៏លើកទ័ពចូលដេញតាមច្បាំងនឹងកងទ័ពចម្បាំងរបស់ពួកកុងទីងទាម ហើយបានសម្លាប់ពួកទ័ពខ្មាំងអស់ជាចំនួនច្រើន មានខ្មោចស្លាប់ពាសពេញទាំងព្រៃព្រះពេជ្រ ។ តពីនោះមក ទើបស្ងប់ការចលាចលរបស់ពួកមេកងទាម ។ គ្រានោះ ពួកខ្មែរចាប់បានឈ្លើយជាចំនួនច្រើន ព្រះចៅតាំងតស្តេចបានព្រះពុទ្ធរូបមាសនឹងប្រាក់ ទើបស្តេចត្រឡប់ចូលមកក្នុងប្រទេសព្រះអង្គព្រមទាំងកងទ័ព ។ តអំពីនោះទ្រង់បានប្រគល់ឲ្យព្រះអនុជ ចៅព្រះកែវហ្វាបញ្ជាការកងទ័ព ១ ដែលមានជោគជ័យឲ្យលើកចេញទៅក្រុងអយុធ្យា ។ ព្រះអង្គស្តេចដល់ទៅពិស្ណុលោក ទ្រង់កសាងព្រះវិហារ ១ នៅជ្រុងទិសអាគ្នេយ៍នៃទីក្រុង ហើយស្តេចឲ្យចេញកងទ័ពទៅ លុះដល់ទៅព្រំដែនប្រទេសអយុធ្យា ស្តេចទ្រង់យល់ថា បើនឹងលើកទ័ពចូលទៅនឹងមានអន្តរាយដល់កងទ័ព ហើយស្តេចត្រឡប់មកជាមួយនឹងកងទ័ពជិតស្រុកពិស្ណុលោកនុ៎ះឯង ។

ព្រះអង្គបានសាងមឿងម្យបុរី(១) ព្រះអង្គទ្រង់តាំងចៅព្រះកែវហ្វាជាចៅហ្វាយខែត្រនៅទីនោះ រួចស្តេចត្រឡប់មកព្រះនគរវិញ ។

---

១ ប្រហែលជាស្រុក បុរីរម្យ សព្វថ្ងៃនេះឯង ។ (មានត)

ពង្សាវតារប្រទេសចិន

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

នេះ ជាឆ្នាំសំខាន់ក្នុងប្រវត្តិសាស្ត្ររបស់ចិន គឺជាឆ្នាំក្បាលតំណក្នុងរវាងសេចក្ដីលំបាកវេទនា និងសេចក្ដីចំរើនរុងរឿងរបស់ចិន ជាឆ្នាំដែលប្រវត្តិសាស្ត្រចិនកំពុងមានរឿងមើលល្អស្ដាប់ ដូចនិទាន (លេងហ៏) បានចាប់លើកត្រង់រឿងសំខាន់ៗ ក្នុងពួកមេទ័ពមេកង ដែលដណ្ដើមរាជបល្ល័ង្ករបស់រាជវង្សស៊ុយ បានសម្រេច គឺឪពុកនិងកូន ២ នាក់ ឪពុកឈ្មោះលីយួន . កូនឈ្មោះលី-ស៊ឺមិន ដែលបានចាប់ផ្ដើមតាំងរាជវង្សថាំង ឡើង ៗ

វគ្គទី ៤

## រាជវង្សថាំង — សម័យព្រះបាទថៃសុងមហារាជ

ឥឡូវនេះមកដល់សម័យប្រវត្តិសាស្ត្រចិន ចំរើនឡើងមកដល់ថ្នាក់បំផុតដោយប្រការទាំងពួង គឺមានអំណាចខ្ពង់ខ្ពស់បំផុត, កាចសាហាវជាបំផុត, ចំរើនរុងរឿងជាបំផុត ហើយធ្វើអំពើថោកទាបជាបំផុត អស់នេះនៅក្នុងសម័យនៃរាជវង្សថាំង ។

រាជវង្សថាំងនោះ បើពោលតាមដោយពិតនោះ គឺឪពុកនិងកូនពីរនាក់ ឈ្មោះ លី - យួន និង លី - ស៊ឺមិន ជាអ្នកតាំងឡើង ៗ

ការពិតនោះ លីយួនជាឪពុកស្ទើរតែមិនបាច់ធ្វើអ្វីឡើយ ការដែលកើតរាជ្យថាំងបានតាំងឡើងក្ដី ការដែលស្រុកចិនបានរួចផុតពីកណ្ដាប់ចេញ បានខ្លួនឆ្ងាយចេញទៅក្ដី ការដែលស្រុកចិនមានសេចក្ដីសុខសប្បាយចំរើនរុងរឿងដោយសារធម៌ ហើយពាសពេញទៅដោយគុណប្រាជ្ញ គឺបណ្ឌិត្យ តាំងពីកកើតជាស្រុកចិនមក មិនដែលមានសម័យណាចំរើនរុងរឿងដូចក្នុងសម័យរាជវង្សថាំងនេះឡើយ ទុកជាក្នុងសម័យសព្វថ្ងៃនេះក៏នៅតែមិនស្មើដែរ ។ កិច្ចការដែលបានសម្រេចដោយស្នាដៃ លី-បេ-មិន សឹងមានពោលទុកក្នុងប្រវត្តិសាស្ត្រចិននេះ ស្ទើរតែកប់ថាជាការចំឡែកបំផុតក្នុងលោក ។

ក្នុងសម័យដែលព្រះបាទ យ៉ុង — ទី បានលះបង់មកុដពជ្ររបស់ក្សត្រប្រទេសចិននោះ លី — បេមិន មានអាយុត្រឹម ២៤ ឆ្នាំ ជាមនុស្សមានលក្ខណៈដូចលោកពីណោ គ្រូសាស្ត្រពោលទុកថា "លី — បេមិន ជាមនុស្សក្មេងខ្ចីតែលែបខាយដូចក្មេងកើតក្នុងកំពង់ ហើយអាចក្លាហានដូចយ៉ាងទាហានដែលចាស់ក្នុងចម្បាំង" ។ ឯលីយួនដែលជាបិតានោះ មានលក្ខណៈជាអ្នកមានពូជពង្សចាស់ មានចិត្តទន់ខ្សោយ ច្រើនមិនហ៊ានធ្វើការធំៗអ្វីទេ តាមដោយពិតនោះ ត្រកូលថាំង ត្រកូលបុណ្យមានបុរមាត់មានមនុស្សរាប់អានច្រើន ក្នុងសម័យដែលស្រុកចិនកំពុងកើតចលាចល ក្នុងផែនដីព្រះបាទ យ៉ុង — ទី នោះ មនុស្សទាំងឡាយក៏ដែរ

មុខទៅរកវង្សត្រកូលថាំង ដែលជាឱកាសល្អបំផុត ឲ្យវង្សត្រកូលថាំង តាំងខ្លួនធ្វើជាធំឡើងបានក្នុងស្រុកចិន តែលី–យួន ជាការពុកកំនៅតែញញើតញញើម មិនប្រាថ្នាប្រើហានធ្វើការអ្វីទេ ទើបលី-ឞេមិនជាកូនចាប់ធ្វើការគ្រប់យ៉ាងដោយខ្លួនឯងទាំងអស់ ជាចំណាងតាងនាមរបស់បិតា ដោយមិនឲ្យបិតាដឹងខ្លួនឡើយ ។ លី–ឞេមិន មានបងស្រីម្នាក់មានលក្ខណាជាស្ត្រីក្លាហានដូចយ៉ាងលី-ឞេមិន ដែលបាននាំយកកងទាហានមកឲ្យលី-ឞេមិនមួយកង ទើបលី-ឞេមិន បានប្រមូលកំឡាំងទាហានយ៉ាងស្រួល ។ ហើយបានទៅចងស្ពានមេត្រីនឹងពួកតួកិមួយរំពេច ដល់ទៅបានធ្វើសម្ពន្ធជាមួយនឹងមេទ័ពពួកតួកិម្នាក់ ទើបប្រមូលកំឡាំងទាហានពួកតួកិមកបញ្ចូលជាមួយផង ហើយលើកកងទ័ពនាំបិតាចូលទៅវាយបានស្រុកស៊ី-អានក្នុងខែណូវែម្ប្រ៍ ពុទ្ធសករាជ ១១៦០ តែមិនបានប្រទូសរ៉ាយធ្វើអន្តរាយដល់ព្រះមហាក្សត្រឡើយ ហើយគាត់តាំងព្រះបាទយ៉ង់-ទីជាក្សត្រកិត្តិយស តមកមិនយូរប៉ុន្មាន ព្រះបាទយ៉ង់-ទីត្រូវគេលួចធ្វើគតទ្រង់ទៅ តែឃាតកកម្មនេះមិនមានប៉ះពាល់សៅហ្មងដល់លី-ឞេមិនទេ ក្នុងឆ្នាំព្រះពុទ្ធសករាជ ១១៦ ។ លី–ឞេមិន បានប្រកាសតាំងបិតារបស់ខ្លួនឡើងជាព្រះចៅអធិរាជក្រុងចិន ហើយតាំងរាជវង្សថ្មីឡើង ដែលជារាជវង្សធំបំផុតរបស់ចិន បានកើតឡើងដោយថ្វៃដៃរបស់ក្មេងកំលោះមានអាយុ ២២ ឆ្នាំ ដោយប្រការដូច្នេះឯង ។

ប៉ុន្តែមុននឹងបានគ្រប់គ្រងខេត្តដែនចិនទូទៅទាំងអស់នោះ លី-ប៉េះ
មិនទឹងបិតា ត្រូវតែទំប្រឹងធ្វើការប្រាបប្រាមពួកមេទ័ពមេកងដែលមាន
កំឡាំងខាបាន កំពុងព្យាយាមតាំងខ្លួនជាស្តេចឡើងតែសព្វខ្លួន ។
ផាន់ជំបូង លី-ប៉េមិនទឹងបិតា ព្យាយាមបង្ក្រាបមេគ្រឹងពួកតួកជួប
ពោលមកហើយ ចំណែកខាងប្រជាជនព្រមទទួលអំណាចរបស់កដវៀង
ចាំង តែត្រឹមខេត្តដែនខាន-ស៊ុ ដែលជាទីលំនៅដើមរបស់ត្រកូលចាំង
នៅកងដែន ប៉េន-ស៊ុ ដែលត្រកូលចាំងទៅតាំងក្រុងនៅស្រុក
ស៊ុ-ង៉ាននោះ គេធ្វើការប្រាបប្រាមបណ្តាខេត្តដែនដែលទទឹងរឹងរូស
ជាវេលា ១៦ ឆ្នាំ ដល់មកក្នុងឆ្នាំព្រះសករាជ ១.១៦៦ ទើប លី-ប៉េមិន
ប្រាបប្រាមខេត្ត ហ៊ូ-ណាន ទើបបានក្រុង ឡោ-យ៉ុង ដែលជាស្រុក
សំខាន់ តមក ៤ ឆ្នាំទៀត ទើបកម្រាប់ប្រាបប្រាមពួករឹងទទឹងនៅខេត្ត
ស្រុក ប៉េ-ប៉េលី ។ ចំណែកឯលីយ៉ួនជាបិតានោះ ជាមនុស្សទន់ខ្សោយ
តាមធម្មតា បណ្តោយព្រះអង្គឲ្យធ្លាក់ទៅនៅក្នុងដៃរបស់ពួកប៉ុនប្រចុប
ចៃចង្កក់ក្នុងកដសំណាក់ ហើយទ្រង់ព្រួសព្រាណពួកដែលកុហកប៉ុន
លើកដំកើងព្រះកិត្តិយស ទើបលី-ប៉េមិនយល់ឃើញថា បើបណ្តោយ
ឲ្យធ្វើដូច្នេះតទៅទៀត កដគណាចក្រពិនដែលខ្លួនខំព្យាយាមតាំងឡើង
នេះ មុខជានឹងសាបសូន្យទៅជាមិនខាន បើដូច្នេះត្រូវតែដកព្រះបិតា
ចេញ តាំងជាព្រះចៅផែនដីកិត្តិយសទៅវិញ ហើយតាំងខ្លួនឯងឡើង

ជាព្រះចៅរាជាធិរាជ ទ្រង់ព្រះនាមថា ព្រះបាទ ថៃ-សុង មហារាជ ទ្រង់គ្រប់គ្រងរាជអាណាចក្រចិនជាវេលា ២៣ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ១.១៧០ ដល់ពុទ្ធសករាជ ១.១៩២ ជាព្រះមហាក្សត្រសំខាន់បំផុតក្នុងពង្សាវតារចិន គឺទ្រង់មានលក្ខណៈជាមនុស្សអត់ធន់ រឹងប៉ឹងម៉ឺងម៉ាត់ ក្លាហានអង់អាចយ៉ាងអស្ចារ្យ មានជួនកាលស្ដេចទ្រង់ពាជីដើរផ្លូវរហូតពេញ ១ ថ្ងៃ ដោយមិនបានសោយអ្វីទៀតក៏មាន, ជួនកាលព្រះចៅថៃ-សុង ទ្រង់គ្រឿងក្រោះនៅជាប់នឹងព្រះអង្គ មិនបានដោះសោះជាវេលាដល់ ៣ ថ្ងៃក៏មាន ។ ការដែលទ្រង់សព្វព្រះទ័យជាបំផុត គឺការដែលទ្រង់ចិញ្ចឹមសេះទុកប្រើការក្នុងសង្គ្រាម នៅផ្នូរព្រះបរមសពរបស់ព្រះបាទ ថៃ-សុង មានព្រះរូបទ្រង់ពាជីដែលទ្រង់ធ្លាប់ប្រើក្នុងសង្គ្រាម មានអក្សរចារឹកប្រាប់ថា ស្ដេចធ្លាប់ទ្រង់ពាជីនោះៗទៅក្នុងទីណាៗខ្លះ រាជពាជីនោះមានរបួសដូចម្ដេចខ្លះ មានរាជពាជីមួយសំខាន់ ហើយទ្រង់ប្រោសប្រាណច្រើននោះ ទ្រង់ប្រទានឈ្មោះថា "ដំណក់ទឹកសន្សើមក្នុងហេមន្តរដូវ" ដែលជាពាជីទ្រង់ប្រើច្បាំងវាយបានស្រុកហ្វូ-ណាន ។

## លី-បេមិន ច្បាំងនឹងពួកតួកិ

ឋានៈរបស់រាជវង្សថាំងនេះ ក្នុងជាន់ដំបូងៗមានសេចក្ដីលំបាកជាច្រើន ពួកតួកិដែលតាំងឡើងឋានខ្លាំងខ្លួន នៅក្បែរព្រំដែនស្រុកចិនដូចពោលមកហើយនោះ ។

(មានត)

វណ្ណគតិ

# នារាយណ៍ ទសាវតារ

អ្នកឧកញ៉ាទេពពិទូរ ក្រ សេម រៀបរៀង (តទៅ)

ចូលចិត្តសិក្សាចំណេះវិជ្ជា វាមនៈទៅជួបពិធីនៅ ឆ្ពោះទូលបិតា ក្រុងពលីពេញចិត្ត ទើបប្រកាសប្រាប់វាមនៈថា ចូលចិត្តសុំអ្វីនឹងឲ្យតាំងអស់ ព្រាហ្មណ៍តឿទើបសុំផែនដីប្រវែង ៣ ជំហានប៉ុណ្ណោះ, ព្រះសុក្រអ្នកជាអាចារ្យបានទូលហាមថា កុំឲ្យទីដីដល់ព្រាហ្មណ៍ឲ្យសោះ តែខំឲ្យខឹងកើតក្តីក្តៅក្រហាយ តែក្រុងពលីបានលាន់វាចាថាឲ្យហើយ ក៏គង់តែឲ្យតាមពាក្យសត្យ ទើបប្រួចទឹកដាក់បាតដៃព្រាហ្មណ៍តឿ ព្រះសុក្រព្យាយាមទទឹងទាស់ បានជំណែងខ្លួនចូលទៅចុកចំពួយកុណ្ឌីទឹកមិនហូរចេញមក វាមនៈដឹងជាមុនហើយ ទើបយកដើមស្បូវទៅចាក់ចំពួយកុណ្ឌី ក៏ត្រូវភ្នែកព្រះសុក្រ ព្រះសុក្រក៏រត់កើនចេញមក ទឹកក៏ហូរចេញមកបាន ស្រេចហើយទើបឈានជំហានយកដីជំហានទី ១ កន្ទឹផុតសុរគត (ទេវលោក) ចាំនមួលជំហានទី ២ ផុតអស់មនុស្សគត ជំហានទី ៣ ជាន់លើក្បាលក្រុងពលី ហើយជាន់សង្កត់លិចទៅដល់ឋានបាតាល(១) ។ លំដាប់នោះព្រះ

---

១ ឋានបាតាលនោះនៅក្រោមមនុស្សលោកនេះ ជាទីនៅនៃនាគ ទៃត្យ ឬ ហៅថា ទៃត្យ, ទានព, យក្ស, និងពួកអសុរ ។ លោកបាតាលនេះតាមក្នុងវិស្ណុបុរាណៈថា មាន ៧ ជាន់មានអ្នកគ្រប់គ្រងតាំងពីជាន់ទី ១ អតល អ្នកគ្រប់គ្រងឈ្មោះមហាមាយៈ, ២ វិតល អ្នកគ្រប់គ្រងឈ្មោះហាតកេស្វរៈ, ៣ សុតល អ្នកគ្រប់គ្រងឈ្មោះពលីពីទៃត្យដែលពោលក្នុងរឿងទសាវតារនេះ, ៤ តលាតលៈអ្នកគ្រប់គ្រងឈ្មោះមាយៈ, ៥ មហាតលៈជាទីនៅរបស់ពស់, ៦ រសាតលជាទីនៅរបស់ទៃត្យនិងទានព, ៧ បាតាលជាទីនៅរបស់នាគមានវាសុកីជាធំ ។ ឋានបាតាលជាន់

នាគយេណរ៍ ក៏ប្រគល់ស្រុកឥា (ឋានសួគ៌) ឲ្យទៅពួកទេវតាវិញ ឲ្យពួកអសុរទាំងប៉ុន្មានទៅនៅឯបាតាលដរាបដល់សព្វថ្ងៃនេះ ។

ប្រហែលទំនងថា ទៅក្រុងទិរ សង្ឃានៅបាតាល កំណាត់ហើយ ចុះទៅជាសំគៀនឲ្យស្ត្រីមនុ ធ្វើពិធីបញ្ចាសរសើរព្រះហរិទេវព្រះស្រី (គឺព្រះលក្ស្មី) ព្រះស្រីអាណាតក៏អង្វរព្រះស្វាមីសុំឲ្យលើកទោសក្រុងពលី, ព្រះវិស្ណុទើបប្រើងក្រទៅតាមក្រុងពលីមកអំពីបាតាលក្រុងកំណត់ឲ្យនៅត្រឹមដែនស្រុកលេ ។ ក្រង់នេះមានសេចក្តីថា ព្រះវិស្ណុត្រាស់ថា [illegible] ទៅគ្រប់គ្រងឋានសួគ៌ដូចដើមវិញ (១) ។

---

១ អាស្រ័យហេតុក្រុងពលីធ្លាប់គ្រប់គ្រងលោកមនុស្សហើយ ៗ បានជាគេជឿថា ទើបប្រើក្តីនឹងបានទៅគ្រប់គ្រងទៀតក្នុងអនាគត ទើបមានមនុស្សនិយមបូជាក្រុងពលីដរាបដល់សព្វថ្ងៃនេះ ប្រហែលជាដោយការរកសាងនៃលោកគាត់ធ្វើទុកពីលើកមុន ។

ក្នុងរឿងនៃរាម ក្រុងពលីខ្មែរយើងថា ព្រះពុទ្ធអង្គបបួលក្រុងពលីភ្នាល់ថា ព្រះអង្គអាចនឹងឈានតែ ៣ ជំហានឲ្យផុតផែនដី, ក្រុងពលីព្រមភ្នាល់ផង ព្រះពុទ្ធតាំងឈានបានតែ ២ ជំហាន ក៏ឈប់សម្រេចសេចក្តីថា ក្រុងពលីចាញ់ ។ ទើបទារកំណល់យ៉ាងធំ សុំហ្មត់ ក៏ប្បក៏មិនបោះអស់គឺ [illegible] ពួកពុទ្ធបរិស័ទ្យ កាលនឹងធ្វើមង្គលការក្តី ឬធ្វើបុណ្យអ្វីក្តី ត្រូវតែនឹងឲ្យក្រុងពលីជាដំបូង, ព្រះពុទ្ធអង្គក៏ធ្វើតាមបង្គាប់ក្រុងពលី ទើបជាប់ជាទំនៀមមកដល់សព្វថ្ងៃនេះ ។

សេចក្តីនេះក្រុមបណ្ឌិតថាជា រឿងកែរឿង ទំនងធ្លាប់តែក្រុងពលីពាំងមិនឲ្យខ្លួនចូលកាន់ពុទ្ធសាសនាហើយនៅតែមិនផ្ដាច់ទើបកែងសេចក្តីវង្វេង ដូច្នេះ ពីយកព្រះនារាយណ៍មកជាព្រះពុទ្ធ យកសំដីរបស់ខ្លួនងងើរទៅប្រើក្នុងព្រះឧស្សាហ៍ ព្រះអង្គបង្គាប់ឲ្យធ្វើដូច្នេះ ។

ក្នុងរឿងស៊ិបប៉ាំងរបស់ហោព្រះសមុត (សៀម) ហៅព្រះនារាយណ៍បែងភាគក្នុងគ្រានេះថា ទុំជាគោរ កប់ជាគ្រាទី ៤ ដំណើររឿងថា មានអសុរ ១ ឈ្មោះតារ៉ុកអសុរ ព្យាយាមទៀងគាល់ព្រះឥសូរជានិច្ច នាថ្ងៃ ១ បានទូលសុំបរិវេណ ៣៦០ យោជន៍ បើសត្វកន្លងចូលទៅក្នុងផែនដីរបស់ខ្លួនហើយ ខ្លួនក៏មានអំណាចចាប់ស៊ីទាំងអស់ ព្រះឥសូរក៏ប្រទានតាមសុំ អសុរក៏កាយមន្តមហាស្នេហ៍ មានទេវតា មនុស្ស និងសព្វសត្វដើរទៅក្នុងបរិវេណនេះ ត្រូវចាប់ស៊ីអស់ជាច្រើន ពួកនេះបានសេចក្តីក្តៅក្រហាយ ក៏ទៅទូលព្រះឥសូរៗ ទើបមានទេវឱង្ការឲ្យព្រះនារាយណ៍អវតារមកបង្រាប គឺបែងភាគជាព្រាហ្មណ៍រូបកំព្រៀវស្រស់សោភា ស្តេចទៅកាន់ផែនតារ៉ុកអសុរ, ក្រុងពលីដើរក្នុងសួនច្បារដោយអំណាចក្តីស្នេហាទើបសួរថា មកដោយប្រាថ្នាអ្វី? ព្រាហ្មណ៍តបស្នងវាចាថា មកសូមផែនដីត្រឹម ៣ ជំហាន, អសុរក៏ព្រមឲ្យដោយស្រួល, ព្រះនារាយណ៍សំដែងឫទ្ធិឈានយកដី ៣ ជំហាន គ្របអស់រហូតទាំងផែនអសុរទៅផង, ក្រុងពលីដឹងថាជាព្រះនារាយណ៍ចុះមកបង្រាបទោមនស្សខ្លាំងណាស់ ទើបទៅអាស្រ័យនៅឯជើងភ្នំសុមេរុ ។

រឿងដី ៣ ជំហាននេះ ខាងខ្មែរបានពោលថា មកអំពីរឿងទេវាសុរសង្គ្រាម ក្នុងជាន់ដើម ពួកអសុរមានឫទ្ធិពូកែ ទើបឈ្នះពួកទេវតា ព្រះវិស្ណុស្តេចគេចទៅនៅទីឆ្ងាយ កុំឲ្យឮសំឡេងអាវុធប៉ះគ្នា, ពួក

ទេវតាបានសេចក្ដីក្ដៅក្រហាយ រឿងចាញ់ប្រៀបពួកអសុរ ទើបទៅអញ្ជើញព្រះអង្គឲ្យមកជួយកំចាត់ ព្រះនារាយណ៍ក៏បែងភាគជាព្រាហ្មណ៍តឿ គ្មានកាន់គ្រឿងអាវុធអ្វី ក្រៅអំពីប្រាជ្ញា មកកាន់ទីបពោះក្រុងទៃត្យៈ ។ ទើបសួរថា មកដើម្បីអ្វី, ព្រាហ្មណ៍សុំឲ្យក្រុងពលិដាក់អាវុធសិន ហើយហាសុំផែនដីប្រវែង ៣ ជំហាន ដើម្បីឲ្យជាទីលំនៅនៃទេពនិករ សល់ក្រៅអំពីនោះនៅជារបស់ក្រុងពលិ ។ លុះគិតឃើញថាជ ៣ ជំហានរបស់ព្រាហ្មណ៍តឿគង់មិនអស់ទៅប៉ុន្មាន ទើបព្រមឲ្យ, ព្រះវិស្ណុក៏សំដែងឫទ្ធិឈានយុគជ ជំហានទី ១ ជាន់ឋានសួគ៌ ជំហានទី ២ ជាន់ឋានមនុស្ស-លោក ជំហានទី ៣ ជាន់ចុះអស់ឋានបាតាល ដោយហេតុនេះព្រះវិស្ណុទើបមាននាមថា "ត្រីវិក្រម[១]" អ្នកឈាន ៣ ជំហាន ។

បរសុរាមាវតារ អវតារគ្រានេះ ដោយវណ្ណក្សត្រមានអំណាចខ្លាំងឡើងបានបៀតបៀនវណ្ណព្រាហ្មណ៍ឲ្យក្ដៅក្រហាយ, ក្នុងគម្ពីរវិស្ណុបុរាណៈពោលថា មានក្សត្រ ១ អង្គព្រះនាមកាធិ ត្រកូលកៅសិក គ្រប់គ្រងនគរកានៃ្យកុព្ជ មានធីតា នាមសត្យវតី ឫសីប្ញចិកៈ ចង់បាននាងជាជាយា តែខ្លួនជាព្រាហ្មណ៍ចាស់នាងមិនព្រមស្រឡាញ់ផង, ព្រះកាធិទើបត្រាស់នឹងឫចិកៈថា បើអាចរកសេះសំបុរសស្អាតត្រចៀកខ្មៅមកថ្វាយបានចំនួនមួយពាន់ទើបនឹងលើកនាងឲ្យ, ឫសីត្រឡប់ទៅរកស្រម

---

១ នៅប្រាសាទព្រៃភាង (អង្គរ) មានឆ្លាក់រូបភាពរឿងឈាន ៣ ជំហាននេះ ។

គាំទ្រពិធីបូជាសួង ព្រះវរុណក៏ទទួលភារៈទៅរកសេះដែលត្រូវការនោះ មកឲ្យបាន ក្រោយនោះ ឫសីចាស់ ក៏បានទានដូចប្រាថ្នា ដំណាមកអ្នកទាំងពីរត្រូវការឲ្យមានបុត្រដំណាវេរ ឫសីក៏តាំងពិធីកូរក្រយាទិព្យ ជា-យាសុំឲ្យកូរជាថ្មីទៀត ដើម្បីថ្វាយព្រះជននី ឫសីក៏សែកក្រយាទិព្យមួយចានឲ្យជាយា ដើម្បីបានបុត្រជាអំបូរព្រាហ្មណ៍ មួយចានទៀតសម្រាប់ថ្វាយព្រះជននី ដើម្បីឲ្យមានឱរសដែលមានឫទ្ធិតេជះ, ស្រេចហើយក៏ចេញទៅព្រៃ តែនាងទាំងពីរបានប្តូរចានបាយគ្នាសោយ ឫសីត្រឡប់មកដឹងរឿងនោះក៏ក្រោធ ព្រោះមិនត្រូវតាមបំណង គឺបុត្រដែលកើតអំពីជាយានោះ នឹងមានលក្ខណៈជាក្សត្រ, ឯឱរសដែលកើតអំពីព្រះជននីនឹងមានចិត្តថ្លើមជាព្រាហ្មណ៍ទៅវិញ តែនាងសុំកុំឲ្យខុសភេទដូច្នោះ បុត្រដែលកើតមកនោះក៏មានលក្ខណៈជាព្រាហ្មណ៍ ឲ្យនាមថា ជមទគ្និ ។

គម្ពីរមហាភារតៈពោលថា ព្រះជមទគ្និទៅដណ្តឹងធីតាព្រះបាទប្រសេនជិត ឈ្មោះនាងរេណុកា មានឱរសកើតជាមួយគ្នា ៥ អង្គ អង្គពៅបំផុតនាមរាម, ព្រះសិវៈប្រទានពូថៅពេជ្រជាអាវុធសម្រាប់អង្គ ទើបមានឈ្មោះថា បរសុរាម (រាមពូថៅ) ។ (មានត)

# អធិប្បាយសុភាសិតខ្មែរ

## ឃុនឧត្តមប្រីជា ជាប-ពិន

រៀបរៀង ( តមក )

### ៦៣ - ឆ្មាមិននៅ កណ្ដុរឡើងរាជ្យ

ពាក្យនេះគេតទៀនក្នុងវេលា

ដែលលោកជាគ្រូមាតា    ចំណាចេញឆ្ងាយចាកកូនចៅ ៗ
កាលម្ដាយឪពុកឬគ្រូបា    មិនទាន់ហៅគ្រាឃ្លាតចេញទៅ
អស់ពួកសិស្សគណឬកូនចៅ    តែងនៅស្ងប់ស្ងៀមគ្រៀមខ្លួនខ្លាច ៗ
សម្ងំដូចកល់សត្វកណ្ដុរ    ខ្លាចឆ្មាអស់រចិត្តកំណាច
ដល់គ្រូចេញៈទៅសិស្សឡើងរាជ្យ    មិនខ្លាចដូចកាលគ្រូនៅឡើយ ៗ
ព្រោះហេតុដូច្នេះទើបលោកថា    ដូចមាតិកាដែលពោលហើយ
អស់សិស្សទាំងកូនទាំងឡាយអើយ    កុំធ្វើគាះគើយត្រូវគោរព ៗ
មាតាបិតានិងគ្រូបា    ឲ្យខ្ជាប់ពួកពាក់ណាទាំងថ្ងៃយប់
ទាំងនៅមិននៅកុំបីឈប់    ដោយគិតប្រារព្ធដល់គុណលោករ

### ៦៤ - ឆ្អឹងដៃស្រែកស្បែកហៅ

ពាក្យនេះអ្នកប្រាជ្ញពីបុរាណ

លោកពោលប្រៀបតាមលំអាន    នៃមនុស្សដែលបានធ្វើអាក្រក់ ៗ
ជាពាក្យបញ្ជាក់ពីហេតុផល    ដែលផ្ដល់ដល់មនុស្សមានចិត្តល្អក់
លបធ្វើអំពើបាបអាក្រក់    តាមចិត្តកក់ម៉ក់ឥតមេត្តា ៗ

លបក៏យកកាប់គេដោយចិត្តខឹង   មិនឲ្យគេដឹងពុតការគ្នា
ហេតុតែផលកម្មដ៏ហានក្លា   មិនបាត់ទៅណាមិនលេស ៗ
ទោះបីខំលាក់បិទបំបាត់   គង់តែមិនស្ងាត់ទីងបាបគ្រោះ
ពេលក្រោយគង់តែផលកម្មនោះ   ឲ្យផលចំពោះអ្នកធ្វើពិត ៗ
បណ្ដាលឲ្យលាន់ពាក្យសំដី   ខ្សឹបប្រាប់ប្រុសស្រីដែលទុកចិត្ត
ដោយក្ដៅស្មារតីពុំបានគិត   ស្មានថាគេបិទគេជួយលាក់ ៗ
តែមិនដូចនោះទេអ្នកអើយ   ផលកម្មនោះហើយតែងទាញទាក់
ត្រឡប់ឲ្យទោសដល់ខ្លួនអ្នក   ដែលធ្វើអប្បលក្ខណ៍នោះពុំខាន ៗ
បណ្ដាលឲ្យគេប្រាប់តទៅ   ដល់ពួកអ្នកក្រៅអាំងប៉ុនាន
ទាល់តែកផការស៊ើបតាមបាន   ដាក់ទោសតាមឋាន៖ក្រឹត្យទោស ៗ

## ៦៥ – ឆ្អងសមគ្គី

សុភាសិតនេះប្រាជ្ញពោលមក

ដើម្បីឲ្យយើងគិតរិះរក   ហើយយកជាគ្រូប្រតិបត្តិខ្លួន ៗ
ដូចការរៀនសូត្រឬការធ្វើ   ដែលជាអំពើល្អមាំមួន
មានផលប្រយោជន៍យ៉ាងខ្ជាប់ខ្ជួន   នាំខ្លួនអ្នកធ្វើឲ្យបានសុខ ៗ
អ្នករៀនអ្នកធ្វើបើមិនទាន់   បានចេះគ្រប់គ្រាន់សព្វគ្រប់មុខ
ប្រឹងរៀនប្រឹងធ្វើខ្លាំងគំហុក   ឲ្យបានគ្រប់មុខសិនសឹមលែង ៗ

បើអ្នកនោះឯងត្រឡប់ឈប់   ក្នុងពេលមិនគ្រប់សព្វគ្រាន់
ដោយគិតចង់រកការខ្លួនឯង   លះបង់ការរៀនប្រសើរនោះ ។
ការងារដែលរៀនយកចំណេះ   បើមិនទាន់ចេះសព្វគ្រប់ស្មោះ
អានិសង្សការរៀនមិនអន្ទ្រោះ   ឲ្យលុះដល់ផលខ្ពង់ខ្ពស់បាន ។
ហេតុនេះទើបប្រាជ្ញប្រាប់ប្រដៅ   ឲ្យខំរៀនទៅលុះចំណាន
ស្ទាត់ស្ទាញមែនមែនទើបឈប់បាន   ដូចបានអង្គុយលម្អសមស្ពុះ ។

### ៦៦ - ដាំងមិនកើត បន្ទោសដែក

ពាក្យនេះអ្នកប្រាជ្ញបុរាណ

លោកពោលតាមរឿងអ្នករចនា   ធ្វើកិច្ចដៃជាងដំទាំងឡាយ ។
កាលធ្វើមិនកើតមិនសម្រេច   ហើយគេចកែប្រែដោះនិយាយ
បន្ទោសអ្នកផងព្រួសព្រាយ   ដល់ផងទាំងឡាយឃើញជាក់ស្តែង ។
ថាវាតែពីអ្នកនេះនោះ   បើឲ្យតែឈ្មោះខ្ញុំម្នាក់ឯង
កុំមានអ្នកណាមកជំនែង   ខ្ញុំធ្វើឲ្យប្រែងល្អយ៉ាងឯក ។
បើធ្វើមិនកើតហើយរកលេស   ហៅ "ដាំងមិនកើតបន្ទោសដែក"
អ្នកមានប្រាជ្ញាគួរបំបែក   ឲ្យបានចម្លែកថែមទៀតចុះ ។

### ៦៧ - ផ្ទះដោះរុនគល់, មិនយល់រុនសក់

ពាក្យថាផ្ទះដោះ គឺអ្នកធំ

ដែលមានស័ក្តិយសខ្ពស់ឧត្តម   សំណាំសំនួនគួរគោរព ។

ដូចយាយនិងតាឬបិតា ឬព្រះពុទ្ធជាចមរៃត្រែគត
ទ្រង់មានព្រះគុណខ្ពស់លើសលុប ឥតអ្វីប្រាក្ដប្រៀបផ្ទឹមបាន ។
ឬមួយព្រះធម៌ព្រះសុគត ដែលអាចរំលត់ទុក្ខឲ្យក្សាន្ត
ទ្រទ្រង់អ្នកកាន់តាំងប៉ុន្មាន ឲ្យបានសុខស្រួលគ្រប់ៗគ្នា ។
អ្នកមានប្រាជ្ញាគេស្គាល់ច្បាស់ ថាមានគុណណាស់ឥតគណនា
តែមនុស្សល្ងង់ខ្លៅចិត្តពាលា បែរជាមិនយល់ប៉ុនធូលី ។
ហេតុនេះអ្នកប្រាជ្ញពីបុរាណ លោកបានប្រដៅដូនប្រុសស្រី
កុំឲ្យមានចិត្តពាលគិរិយ គប្បីគោរពឲ្យណាស់ណា ។

## ៦៨ - ឈើពុកកុំជាកាំគួនលើ

ពាក្យនេះបុរាណលោកឃាត់ហាម

មិនឲ្យពួកជនប្រព្រឹត្តតាម នូវស្នាមមនុស្សពាលពុតល្ងង់ខ្លៅ ។
ធម្មតាឈើពុកតែងដាច់បាក់ បើជនណាដាក់ជន្ទុយនៅ
តែងបាក់លំជួលដេកទៅ ធ្វើឲ្យហិនសៅដល់ខ្លួនប្រាណ ។
សេចក្ដីនេះឯងមានឧបមា ដូចមនុស្សពាលាពុតសាមាន្យ
តែងធ្វើអ្នកគប់ផងឲ្យបាន ទុក្ខទោសជះប្រាណមិនបានសុខ ។
ហេតុនេះលោកប្រើគប់អ្នកប្រាជ្ញ ព្រោះអាចណែនាំឲ្យរួចទុក្ខ
មិនឲ្យគប់ពាលនាំពលិយក ដូចគល់ឈើពុកកំដាក់គខ ។

### ៦៩ - ញៀននឹងល្បែងតែងអាប់យស

ពាក្យនេះជាពាក្យពោលប្រឌិត

ប្រដៅមហាជនឲ្យប្រព្រឹត្ត    កាន់ចិត្តគំនិតត្រឹមត្រូវល្អ ៗ
ការល្បែងទាំងពួងលោកអភិប្រាយ    ថាជាអបាយមុខចំហ
ជាគ្រឿងបណ្ដាលនឹងបង្ក    ឲ្យកើតមិនល្អដល់សន្តាន ៗ
អ្នកញៀននឹងល្បែងទោះមានយស    សក្តិធំខ្ពស់ច្រើនប៉ុន្មាន
រមែងត្រឡប់ទៅជាបាន    កើតទុក្ខរំខានខ្សត់ក្រទាល់ ៗ
ឯល្បែងលោកពោលថាមានបី    គឺល្បែងស្រាស្រីនឹងល្បែងភ្នាល់
ទាំងនេះអ្នកលេងតែងប៉ះពាល់    ទុក្ខទោសក្រទាល់អាប់សិរី ៗ

### ៧០ - ដល់ត្រើយសើយគូទឲ្យ

ពាក្យនេះប្រាជ្ញពោលជាគម្រូ

ទុកប្រាប់ពួកជនអកតញ្ញូ    ដែលឥតគិតគុណគេសោះ ៗ
គឺកាលដែលខ្លួនមានគ្រោះថ្នាក់    រត់ទៅពឹងពាក់អ្នកណានោះ
ឲ្យគេមេត្តាជួយសង្គ្រោះ    រំដោះគ្រោះថ្នាក់ដែលខ្លួនមាន ៗ
ប៉ុន្តែត្រឡប់ធ្វើអាក្រក់    ភក់មក់ព្រហើនភ្លេចឈ្មោះបាន
ប្រមាថមើលងាយលោកអ្នកមាន    គុណផងប្រណាំងទៅថ្ងៃក្រោយ ៗ
យ៉ាងនេះអ្នកប្រាជ្ញបុរាណ    ហៅថា "ដល់ត្រើយសើយគូទឲ្យ"
ជាពាក្យប្រដៅយើងជាន់ក្រោយ    កុំឲ្យលុបគុណអ្នកមានគុណ ៗ

### ៧១- ដាក់ត្រីឲ្យស្រាស់បន្លា, អាះសាច់ជូនខ្លា
### ទើបទៅស្រុកចាន

ពាក្យនេះបុរាណលោកប្រឌិត

ឲ្យពួកមហាជនបេះគន់គិត    ប្រុងល្អិតចិត្តអ្នកផងទៃ ។
ដូចអ្នកដែលៈនាំក្ដីសំណាក់    លោកអ្នកណាមួយគួរបេះលៃ
បេះគិតពិនិត្យឲ្យប្រពៃ    កៃរះយកចិត្តគេទើបបាន ។
ធ្វើកាយវាចាកុំឲ្យយើស    កុំលើសឲ្យល្មមសមប្រមាណ
ត្រូវស្ងួតកុំកាចកុំឈ្លានពាន    ទើបបានសុខស្រួលយូរអង្វែង ។
បើមិនយកចិត្តគេផលតិច    ធ្វើម្ដេចគេនឹងយកចិត្តឯង
ផលមានរលស់គេបំបែង    មិនជួយឲ្យឯងបានសុខា ។
ហេតុនេះលោកពោលជាគំរូ    ដូចអ្នកដាក់ត្រីត្រូវស្រាហ៍
ស្រាស់ទួរសប្រាស់បន្លា    ទើបបានសុខាដូចបំណង ។

### ៧២— ដីដ្ដើយដៀតដាប់ ក្លួនឥត
### ច្បាប់ព្រះមេចា[1]

ពាក្យនេះអ្នកប្រាជ្ញពីបុរាណ

លោកពោលប្រដៅឲ្យយើងបាន ដឹងតាមលំអាននៃធម្មតា ។

---

១ ន័យៗ ជា ដីគៈផ្ញើយត្បៀតជិត ក្លូនឆ្លងព្រោះមេឃា ។

ចំនៀមពួកជាងអ្នកធ្វើផង   បើទងសង្កេតក៏ឃើញថា
ពួកជាងគេធ្វើដោយប្រាជ្ញា   បំពេញវិជ្ជានៃអ្នកផង ។
បើជាប់មិនល្អជំនិងធ្វើយ   ក៏ផ្ទើយៗ នាំពេកកន្ទង
យកទៅកាប់ចាំងអស់ឈើផង   សំងំខុសទំនងចាំងពុំបាន ។
នេះដូចបុត្រានិងបុត្រី   គឺកូនប្រុសស្រីទាំងប៉ុន្មាន
ដែលមានសណ្ដាប់ព្រោះតែបាន   មេបាទូន្មានយ៉ាងចំណាប់ ។
បើម្ដាយឪពុកមិន[illegible]ផ្ទៅ   កូនចៅទាំងពួងនឹងឥតបង្ក្រាប
ហេតុនេះអ្នកប្រាជ្ញចាស់លោកប្រាប់   ថា "កូនឥតបង្ក្រាប់ព្រោះមេបា" ។
បើបុត្រធ្វើខុសគួរតិះដៀល   មិនមានដំនៀលត្រឹមបុត្រា
ប្រែនតែតិះដៀលដល់មេបា   ថា "កូននរណាឥតពូជម្ល៉េះ!" ។

(មាគត)

កណ្ហាតិណ្ហាកជាតក

# តិសតិនិបាត សត្តមភាគ

ព្រះបាទឡាត់ពោធិកម ប៉ូរ - ប៉ុណ្ណ ក្រុមជំនុំព្រះត្រៃបិដក

ប្រែនិងរៀបរៀង ( តមកនឹង ចប់ )

ម្នាលព្រាហ្មណ៍ កាលបើភ័យយ៉ាងនេះកើតឡើងហើយ មនុស្សទាំងឡាយដែលលំបាកដោយភ័យ ( យ៉ាងនេះ ) ទើបបានជានាំគ្នាយកបន្ទាកនៃព្រៃមកធ្វើជាទីសម្រាប់ពឹងពួន ។

ព្រះបាទព្រហ្មទត្តបានទ្រង់ព្រះសណ្ដាប់ពាក្យបុរសចាស់នោះហើយ ក៏ហៅបុរោហិតមកប្រាប់ថា បុរសចាស់នេះនិយាយត្រូវណាស់ មកយើងនឹងត្រឡប់ទៅសោយរាជ្យឲ្យប្រកបដោយធម៌វិញ ។

ទើបទេវតាពោធិសត្វបញ្ចូលចិត្តបុរោហិតឲ្យទូលស្ដេចថា សូមឲ្យព្រះអង្គយាងទៅឈ្លបស្រុកឯទៀត ៗ មើលសិន ស្ដាប់ការស្ដាប់ដំណឹងឲ្យបានដឹងហេតុសព្វគ្រប់ ហើយសឹមយាងទៅសោយរាជ្យប្រព្រឹត្តទសពិធរាជធម៌ឲ្យគ្រប់គ្រាន់ ។ ស្ដេចក៏យាងចេញអំពីស្រុកនេះទៅកាន់ស្រុកមួយទៀត បានទ្រង់ព្រះសណ្ដាប់សំឡេងស្ត្រីចាស់ម្នាក់កំពុងតែជេរស្ដេច ។

ឯស្ត្រីចាស់នោះ ជាអ្នកក្រីក្រលំបាក មានកូនស្រីពីរនាក់មិនទាន់មានប្ដីនៅឡើយ ម្ដាយក្រោមិនឲ្យដើរទៅណាមកណាទេ ដើរទៅរកស៊ីធ្វើការដោយខ្លួនឯង, ចិញ្ចឹមកូនស្រី ថ្ងៃនោះស្ត្រីចាស់កំពុងឡើងដើមឈើបេះអន្លក់ ក៏ស្រាប់តែធ្លាក់ពីដើមឈើ ហើយជេរស្ដេចថា:

កោធស្ស ធាម យំ កជ្ជា ព្រាហ្មណោ មរិស្សតិ
យស្ស រដ្ឋម្ហិ ជីយន្តិ អប្បតិកា កុមារិកា ។

ពួកកុមារីជាស្រ្តីគ្មានប្តី រមែងចាស់ទៅក្នុងដែននៃស្តេចព្រហ្មទត្ត
ឯណា ព្រះបាទព្រហ្មទត្តនោះ នឹងស្លាប់ទៅក្នុងកាលណាអេះ ។

បុរោហិតបានឮហើយឃាត់ថា:

ទុព្ភាសិតញ្ហិ តេ ជម្មិ អនត្ថបទកោវិទេ
កុហឹ រាជា កុមារីនំ ភត្តារំ បរិយេសតិ ។

នែនាងលាមក ជាស្រីមិនឈ្លាសក្នុងហេតុនិងផល ពាក្យនាងឯង ជាពាក្យអាក្រក់ តម្បាលយ៉ាងស្តេច មកស្វែងរកប្តីឲ្យពួកនាងកុមារីដូចម្តេចកើត ។

ស្រ្តីចាស់នោះឆ្លើយតបថា:

ន មេ ទុព្ភាសិតំ ព្រហ្មេ កោវិទត្ថបទា អហំ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។
រត្តិំ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។
ទុជ្ជីវេ ទុព្ភរេ ទារេ កុតោ ភត្តា កុមារិយា ។

នែព្រាហ្មណ៍ ពាក្យនាងខ្ញុំមិនអាក្រក់ទេ នាងខ្ញុំជាស្រ្តីឆ្លៀវឆ្លាស ក្នុងហេតុនិងផលដែរ ពួកអ្នកជនបទ ក៏ស្តេចមិនរក្សាទេះតែបៀតបៀន

ដោយស្មួយសារភាគ មិនប្រកបដោយធម៌ទេ ។ ពិតណាស់ក្នុងវេលា យប់ ពួកចោរដើរប្លន់អ្នកស្រុក, វេលាថ្ងៃ ពួកអ្នកយកការប្លន់ក្រស្ដី ព្រោះតែស្ដេចខូចកាចលោភយកពន្ធដែល បានជាជនច្រើនតែមិនប្រកប ដោយធម៌ កាលបើស្ត្រីរស់នៅដោយលំបាក ទាំងប្រពន្ធដែលគេ ចិញ្ចឹមក៏បានដោយលំបាក (យ៉ាងនេះ) តើពួកនាងកុមារីបានប្ដីពីណា កើត ។

— ស្ដេចទីងបុរោហិតបានស្ដាប់ហើយគិតថា ស្ត្រីនេះនិយាយត្រូវណាស់ ហើយក៏យាងហួសទៅទៀត, បានឮសំឡេងអ្នកស្រែម្នាក់ ផាល មុតជើងគោ ក៏ស្រែកជេរស្ដេចថា:

ឯវំ សយេតុ បញ្ចាលោ សង្គាមេ សត្តិយា ហតោ យថាយំ កបណោ សេតិ ហតោ ផាលេន សាលិយោ ។

គោឈ្មោះសាលិយៈនេះ ជាសត្វកំព្រាត្រូវផាលមុតជើងដេកស្រែក យ៉ាងណា សូមឲ្យស្ដេចបញ្ចាលត្រូវគេសម្លាប់ដោយលំពែងក្នុងសង្គ្រាម ដេកស្លូកយ៉ាងនោះចុះ ។

បុរោហិតឃាត់អ្នកស្រែនោះថា:

អធម្មេន តុវំ ជម្ម ព្រហ្មទត្តស្ស កុជ្ឈសិ
យោ ត្វំ សបសិ បញ្ចាលំ អបរជ្ឈិត្វាន អត្តនោ ។

នែបុរសណាមក អ្នកឯងដែលប្រុះខ្ទីងខឹងនឹងស្ដេចរបស់ខ្លួន អ្នកឯង ឈ្មោះថាខឹងទៅរកស្ដេចព្រហ្មទត្ត ដោយហេតុមិនត្រូវតាមធម៌ទេ ។

អ្នកក្រុសស្ដាប់នូវពាក្យនោះហើយ ពោលតបថា:

ជនេន្ទ ព្រហ្មទត្តស្ស អហំ កុជ្ឈាមិ ព្រាហ្មណ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។
រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។
សានូន បុន រេ បក្កា វិកាលេ ភត្តមាហារិ
ភត្តហារី អវេក្ខន្តោ ហតា ជាលេន សាលិយោ ។

ម្នាលព្រាហ្មណ៍ ខ្ញុំខឹងចំពោះស្ដេចព្រហ្មទត្ត ដោយហេតុត្រូវតាមធម៌ (ព្រោះថា) ពួកអ្នកជនបទ ស្ដេចមិនដែលរក្សាទេ បេះតែបៀតបៀនដោយសួយសារអាករ មិនប្រកបៈដោយធម៌ ។ ពិតណាស់ ក្នុងវេលាយប់ ពួកចោរប្លន់ (អ្នកស្រុក) វេលាថ្ងៃ ពួកអ្នកជការប្លន់ (កស្ដ្រ ព្រោះតែ) ស្ដេចខូចកាចសោយរាជ្យក្នុងដែន ‑ បានជាជនច្រើន តែមិនប្រកបដោយធម៌ ។ ស្ដ្រីជាអ្នកដាំបាយក្នុងវេលាព្រឹក (នាំយកមក ឲ្យខ្ញុំ ក៏ត្រូវខ្ញុំកំដររបស់ស្ដេចព្រហ្មទត្តរឹបជាន់យកបាយអស់) លុះវេលា ថ្ងៃរសៀលទើបនាំយកបាយមក (ឲ្យខ្ញុំ) ខ្ញុំក៏ចាំមើល នូវស្ដ្រីអ្នក យ៉ាបាយមកឲ្យ ចាំងគោឈ្មោះសាលិយៈ ក៏ត្រូវផាលមុតជើងទៀត ។

ស្ដេចនឹងបុរោហិតឮហើយក៏ទៅស្រុក ១ ទៀត ។ បុរសអ្នករែកទឹក-ដោះមេគោ ក៏ត្រូវមេគោជាន់ធ្លាក់ភាជន៍ទឹកដោះពីដៃហើយក៏ជេរស្ដេចថា:

ឯវំ ហញ្ញតុ បញ្ចាលោ សង្គាមេ អសិនា ហតោ
យថាហមជ្ជ បហតោ ខីរញ្ច មេ បវត្តិតំ ។

ក្នុងថ្ងៃនេះ ខ្លួនអញត្រូវមេគោជាន់ ទាំងទឹកដោះក៏ធ្លាក់ពីដៃរបស់អញយ៉ាងណា សូមឲ្យស្ដេចបញ្ចាលត្រូវគេសម្លាប់ដោយដាវក្នុងសង្គ្រាមលំបាកយ៉ាងនោះចុះ ។

បុរោហិតឮហើយ សួរថា:

-អយំ បសុ ខីរំ ឆឌ្ឌេសិ បសុ ជាលញ្ច ហឹសតិ
កោ តត្ថ ព្រហ្មទត្តស្ស យំ នោ គរហតេ ភវំ ។

សត្វចិញ្ចឹមនេះរមែងបោលនូវទឹកដោះ សត្វចិញ្ចឹមរមែងបៀតបៀននូវផាល ដោយហេតុឯណា អ្នកមិនគួរតិះដៀលនូវស្ដេចដ៏ចំរើន ដោយហេតុឯណា កំហុសរបស់ស្ដេចព្រហ្មទត្ត ចំពោះហេតុនោះ ។ តើដូចម្ដេច?

បុរសអ្នករែកទឹកដោះឆ្លើយតបវិញថា:

គារយ្ហោ ព្រហ្មេ បញ្ចាលោ ព្រហ្មទត្តស្ស រាជិនោ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។
រត្តិ ច ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា

រដ្ឋស្មឹ ក្ខុដរាជស្ស ពហុ អធម្មិកោ ជនោ ។

ចណ្ឌា អតគ្គធា តាវី យំ បុរេ ន ទុហាមសេ

តំទានិ អជ្ជ ទោហាម ទីរកាមេ បហុបុត្តា ។

ម្នាលព្រាហ្មណ៍ ស្តេចបញ្ចាលរបស់រាជត្រកូលព្រហ្មទត្ត គួរអ្នកផងគេតិះដៀលហើយ (ព្រោះថា) ពួកអ្នកជនបទ ស្តេចមិនដែលជួយរក្សាការពារទេ បេះតែបៀតបៀនដោយស្មួយសារអាករ មិនប្រកបដោយធម៌ ។ ពិតណាស់ តែគង់វេលាយប់ ពួកចោរដើរប្លន់ (យកទ្រព្យសម្បត្តិអ្នកស្រុក) វេលាថ្ងៃ ពួកអ្នករាជការប្រៀបជាន់ប្លន់ (ក ស្តេ) (ព្រោះតែ) ស្តេចខូចកាចសោយរាជ្យក្នុងដែន បានជាជនច្រើនតែមិនប្រកបដោយធម៌ ។ មេគោកាចផ្ទាំង ក្នុងកាលពីមុនយើងមិនបានរឹតទឹក-ដោះឯណា ក្នុងថ្ងៃនេះ ឥឡូវនេះ ពួកយើងក៏ត្រូវពួករាជបុរសអ្នកប្រាជ្ញនូវទឹកដោះមករឹបជាន់ ទើបរឹតទឹកដោះនោះ (បើស្តេចសោយរាជ្យប្រកបដោយធម៌ ភ័យមិនមានដល់យើងទេ) ។

ស្តេចនឹងបុរោហិតនិយាយថា បុរសនេះថាត្រូវណាស់ ហើយក៏ចៀសចេញទៅកាន់ស្រុកមួយទៀត ។ សម័យមួយ ពួកអ្នករាជការសម្លាប់កូនគោយកស្បែកធ្វើស្រោមដាវ មេគោក៏គេត្តូតាដោយសេចក្តីសោកស្តាយកូនរបស់ក ។ ពួកគេនឹងអ្នកស្រុកជាអ្នកឃ្វាលគោ ក៏ស្រែកជេរស្តេចថា:

ឋិតំ កណ្ឌុតុ បញ្ចាលោ វិមុត្តោ បរិធាវតុំ
យថាយំ កាបលា គាវី វិមុត្តា បរិធាវតិ ។

មេគោនេះក៏ព្រាជាសត្វព្រាត់ព្រាស (កូន) ស្ទុះទ្រុទ្រាយយ៉ាងណា សូមស្ដេចបញ្ចាលព្រាត់ព្រាសទិកសរីរ៍ស្រុកកន្ទុកកន្ទេញយ៉ាងនោះចុះ ។

បុរោហិតសួរថា :

— យំ បទុ បសុបាលស្ស បត្តមេយ្យ រវេយ្យ វា
គោ ធីជ អបភជត្តំ ព្រហ្មទត្តស្ស វាជិនោ ។

កាលដែលបុរសអ្នកក្សាទូសត្វចញ្ចឹម ចំណែកនាទសត្វចិញ្ចឹមក៏ស្ទុះទ្រុទ្រាប្ដ់ស្រែកដោយហេតុឯណា កំហុសរបស់ស្ដេចព្រហ្មទត្តមែនមានក្នុងហេតុនេះ តើដូចម្ដេច ។

ពួកក្មេង១អ្នកស្រែកឆ្លើយតបថា:

អបភោ មហាព្រហ្មេ ព្រហ្មទត្តស្ស វាជិនោ
អរញ្ញេ ជានបទា អធម្មពលិនា ហតា ។
រត្តិ ច ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ
ការំ ជោ អសិកោសត្វា វីរធា ហញ្ញតេ បជា ។

បពិត្រមហាព្រាហ្មណ៍ កំហុសរមែងមានដល់ស្តេចព្រហ្មទត្តដោយពិត ព្រោះថា ពួកអ្នកជនបទ ស្តេចមិនដែលរក្សាដល់ម្តងទេ ចេះតែបៀតបៀនដោយសួយសារអាករ មិនប្រកបដោយធម៌ ៗ តែគង់វេលាយប់ ពួកចោរដើរប្លន់ (អ្នកស្រុក) វេលាថ្ងៃ ពួកអ្នករាជការរឹបជាន់ប្លន់ (ពីស្រុក) តាមអំណាច ព្រោះតែស្តេចខូចការសោយរាជ្យគ្រងដែន (មិនប្រកបដោយធម៌) បានជាជនច្រើនតែមិនប្រកបដោយធម៌ដែរ កូនខ្ចីនៅកំពុងតែបៅដោះ មានប្រយោជន៍ដល់ស្រាមដាវ រមែងលំបាកយ៉ាងណាទៅ ៗ

ស្តេចទីន់បុរោហិតនិយាយថា ពួកក្មេង ៗ អ្នកស្រុកនេះចេះទំនាយត្រូវណាស់ហ្ន៎! ហើយក៏ចៀសចេញទៅ ៗ គ្រានោះ ពួកក្អែកកំពុងតែចាប់ចឹកកង្កែបស៊ីជាអាហារ ក្នុងស្រះបោក្ខរណី ១ ដែលទឹកអស់ ក្នុងវេងពាក់កណ្តាលផ្លូវ, ព្រះពោធិសត្វក៏បណ្តាលឲ្យកង្កែបជេរស្តេចថា:

ឯវំ ខជ្ជតុ បញ្ចាលោ ហតោ យុទ្ធេ សបុត្តកោ
យថាហមជ្ជ ខជ្ជាមិ គាមិកេហិ អរញ្ញជោ ៗ

អាត្មាអញកើតក្នុងព្រៃ ត្រូវពួកក្អែកក្នុងស្រុកចឹកស៊ីក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យស្តេចបញ្ចាលព្រមទាំងបុត្រ ត្រូវគេកាប់ក្នុងចម្បាំងដាច់ខ្ទេចខ្ទីយ៉ាងនោះចុះ ៗ

បុរោហិតស្តាប់ហើយ និយាយនឹងកង្កែបថា :

ន សព្វភូតេសុ វិធេន្តិ រក្ខំ
រាជានោ មណ្ឌូក មនុស្សលោកេ
នេត្តាវតា រាជា អធម្មចារី
យំ តាទិសំ ជីវមទេយ្យុ ធង្កា ។

៙ ឱកង្កែប ព្រះរាជាទាំងឡាយ ក្នុងមនុស្សលោក (នេះ) មិនចាត់ចែងនូវការរក្សាចំពោះពួកសត្វទាំងឡាយទេ ពួកក្អែកស៊ីនូវសត្វស្រែប្រាកដដូច្នោះ ដោយហេតុឯណា ព្រះរាជាមិនមែនប្រព្រឹត្តមិនប្រកបដោយធម៌ ដោយហេតុប៉ុណ្ណោះទេ ។

កង្កែបស្តាប់ហើយនិយាយតបវិញថា :

អធម្មរូបោ វត ព្រហ្មចារី
អនុប្បិយំ ភាសសិ ខត្តិយស្ស
វិលុម្បមានាយ បជាយ
បូជេសិ រាជំ បរមប្បវាទី ។
សចេ ឥទំ ព្រហ្មេ សុរដ្ឋកំ សិយា
ផីតំ រដ្ឋំ មុទិតំ វិប្បសន្នំ
ភុត្វា ពលិំ អគ្គបិណ្ឌញ្ច កាកា
ន មាទិសំ ជីវមទេយ្យុ ធង្កា ។

អ្នកដូចជាព្រហ្មចារីបុគ្គល តែមានសភាពមិនមែនជាអ្នកធម៌ សោះ ពោលនូវពាក្យគួរដល់សេចក្ដីស្រឡាញ់ចំពោះក្សត្រ កាលបើប្រែជាផង ជា ច្រើនដែលស្ដេចរំលងជាន់ អ្នកបូជា (សរសើរ) ចំពោះស្ដេចថាជា អ្នកមិនពោលពាក្យដ៏ប្រសើរ ។ នៃព្រះករុណា ប្រសិនបើដែននេះមាន រាជការល្អ ជាដែនសុកសម្ល មានពស្ត្រីកកយ ដ៏រុះថ្លា ទាំងពួកក្អែក ក៏បានស៊ីនូវដុំបាយដ៏ប្រសើរ ជាគ្រឿងបូជា (របស់មនុស្ស) ពួកក្អែក នឹងមិនស៊ីសត្វរស់ ព្រោកដដូចជាខ្ញុំមិនមាន ។

ហេតុដែលដេរបញ្ចូសដល់ស្ដេចទាំង៦ កន្ទុងនេះ គឺដោយអំណាច ពោធិសត្វមកបញ្ចូលចិត្ត ឲ្យអ្នកទាំងអស់គ្នាគិតឃើញយ៉ាងនេះ ដើម្បី នឹងរំឭកស្ដេចបញ្ចាលឲ្យលោកបានប្រព្រឹត្តតែមត្រូវតាមទសពិធរាជធម៌, ឲ្យពួកជនដែលអាស្រ័យនៅក្នុងដែនបានសេចក្ដីសុខក្សេមក្សាន្ត ដោយ សារគុណបុណ្យបារមីរបស់ស្ដេចតទៅ ។

៦ព្រះបាទបញ្ចាលនឹងបុរោហិត លុះបានឮនូវហេតុនោះហើយក៏ វិលត្រឡប់ទៅនគរគ្រប់ត្រងកដ្បដូចដើមវិញ ទទួលយកនូវឱវាទនៃ ពោធិសត្វមកដាក់ទុកក្នុងព្រះទ័យ ហើយចាត់ចែងរៀបចំការរាជការ ក្នុងព្រះនគរឲ្យបានរៀបរយតាមបវេណី ប្រព្រឹត្តនូវទសពិធរាជធម៌ ដោយគ្រប់គ្រាន់, ពួកប្រជាក៏បានសេចក្ដីសុខ-ចំរើន, ទាំងភោគ-សម្បទក៏សម្បូណ៌សប្បាយបាយវាយឥតខ្វះខាតឡើយ ។

ព្រះមានព្រះភាគទ្រង់នាំអតីតនិទានមកពន្យល់ដល់ព្រះរាជាកោ-សលដូចបានអធិប្បាយមកនេះ ហើយទ្រង់រំឭកដាស់តឿនថា បពិត្រមហារាជ សូមឲ្យមហារាជលះបង់នូវអគតិចេញ ហើយគ្រប់គ្រងរាជ្យប្រកបដោយធម៌ចុះ ។

ចប់ភណ្ឌុតិណ្ឌុកជាតកតែប៉ុណ្ណោះ ។

លោកគ្រូព្រះអាចារ្យ ប៉ាង-ខាត់ រៀបរៀង

(តមក)

## ទ្រង់ប្រកាសអរិយសច្ច មិនយកបិត្តអ្នកណា ឬមិនយល់មុខអ្នកណា

ម្នាលភិក្ខុទាំងឡាយ! ក្នុងកាលពីដើមក្តី ឥឡូវនេះក្តី តថាគតតែងបញ្ញត្តនូវទុក្ខផង នូវសេចក្តីរលត់នៃទុក្ខផង(១) ។ ម្នាលភិក្ខុទាំងឡាយ! បើពួកជនដទៃជេរ គម្រាម ប្រទូស្ត បៀតបៀន ធ្វើបាបតថាគតក្នុងការប្រកាសសច្ចទាំង ៤ នោះ ម្នាលភិក្ខុទាំងឡាយ! សេចក្តីក្រោធក៏មិនមាន សេចក្តីមិនត្រេកអរគឺទោមនស្សក៏មិនមាន សេចក្តីមិនរីករាយនៃចិត្តក៏មិនមាន ដល់តថាគត ក្នុងហេតុមានជេរជាដើមនេះទេ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃធ្វើសក្ការៈ គោរពរាប់អាន បូជាតថាគតក្នុងការប្រកាសសច្ចនោះវិញ ម្នាលភិក្ខុទាំងឡាយ! សេចក្តីត្រេកអរក៏មិនមាន សេចក្តីសោមនស្សក៏មិនមាន សេចក្តីបានចិត្តក៏មិនមាន ដល់តថាគត ក្នុងសក្ការៈជាដើមនោះទេ ។ ម្នាលភិក្ខុទាំងឡាយ! បើពួកជនដទៃធ្វើសក្ការៈ គោរពរាប់អាន បូជាតថាគតក្នុងការប្រកាសសច្ចនោះ; ម្នាលភិក្ខុទាំងឡាយ! តថាគតមានសេចក្តីត្រិះរិះក្នុងសក្ការៈជាដើមនោះយ៉ាងនេះថា: "ខន្ធបញ្ចកៈ

---

១ សង្គ្រោះយកអរិយសច្ចទាំង ៤ ប្រការ

ឯណា ដែលតថាគតបានកំណត់ដឹងក្នុងកាលមុនរួចហើយ សក្ការៈមានសភាពយ៉ាងនេះៗ ដែលពួកជនដទៃធ្វើដល់តថាគត ក៏បំពោះរន្ធ-បញ្ញកៈនោះទេ" ៗ

ម. មូ. អលគទ្ទូបមសូត្រ ២១-៦៤-២៤

## សាវ័កអាស្រ័យនៅនឹងតថាគត ព្រោះតថាគតអាចឆ្លើយប្រស្នាអរិយសច្ចបាន

ម្នាលឧទាយិ! . . . បើពួកសាវ័កធ្វើសក្ការៈ គោរព រាប់អានបូជាតថាគត . . . ដោយគិតថាៈ "ព្រះសមណគោតម ព្រះអង្គមានអាហារតិចផង សរសើរបែបភាពរបស់បុគ្គលអ្នកមានអាហារតិចផង" . . . ម្នាលឧទាយិ! ពួកសាវ័កឯណារបស់តថាគត ដែលគេមានអាហារត្រឹមមួយកូនផ្តិលខ្លះ មានអាហារត្រឹមកន្លះកូនផ្តិលខ្លះ មានអាហារមួយសម្បកផ្លែព្នៅខ្លះ មានអាហារកន្លះសម្បកផ្លែព្នៅខ្លះ, ពួកសាវ័កទាំងនោះ ក៏មិនសមឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត . . . ដោយធម៌គឺអាហារតិចនេះឡើយ ៗ

ម្នាលឧទាយិ . . . បើពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយគិតថាៈ "ព្រះសមណគោតម ទ្រង់សន្តោសដោយចីវរតាមមានតាមបាន" ម្នាលឧទាយិ! ពួកសាវ័កឯណា របស់តថាគត ដែល

គេប្រើប្រាស់ត្រៃមានសំពត់បង្សុកូល ទ្រទ្រង់នូវចីវរសៅហ្មង ពួកគេរើសនូវកំណាត់សំពត់អំពីព្រៃស្មសានខ្លះ អំពីគំនរសម្រាមខ្លះ អំពីកន្លែងផ្សារខ្លះ ធ្វើជាសង្ឃាដីប្រើប្រាស់, ពួកសាវកទាំងនោះមិនសមឈ្មោះថា ធ្វើសក្ការៈគោរព កប់អាន បូជាតថាគត . . . ដោយធម៌គឺសេចក្តីសន្តោសនេះឡើយ ។

ម្នាលឧទាយិ! . . . បើពួកសាវកធ្វើសក្ការៈ គោរព កប់អាន បូជាតថាគត . . . ដោយគិតថា "ព្រះសមណគោតម ត្រេកអរសន្តោសដោយបិណ្ឌបាតតាមមានតាមបាន សរសើរសេចក្តីសន្តោសដោយបិណ្ឌបាតតាមមានតាមបាន" . . . ម្នាលឧទាយិ! ពួកសាវករបស់តថាគត ប្រព្រឹត្តបិណ្ឌបាត ត្រាច់ទៅតាមលំដាប់ច្រក ត្រេកអរក្នុងវត្ត គឺការឈរតាមទ្វារផ្ទះត្រកូលខ្ពស់និងទាប, សាវកទាំងនោះ រមែងចូលទៅកាន់ចន្លោះផ្ទះ បើទុកជាគេនិមន្តដោយអាសនៈក៏មិនត្រេកអរ, សាវកទាំងនោះ មិនសមឈ្មោះថាធ្វើសក្ការៈគោរព កប់អាន បូជាតថាគត ដោយធម៌គឺសេចក្តីសន្តោសនេះឡើយ ។ល។ . . . . . . . . . . . . . . .

ម្នាលឧទាយិ! មួយវិញទៀត ពួកសាវករបស់តថាគត មានទុក្ខបៀតបៀនហើយ មានទុក្ខគ្របសង្កត់ហើយ ពួកសាវកទាំងនោះ ចូលមករកតថាគតហើយ សួរទុក្ខអរិយសច្ច សេចក្តីពិតដ៏ប្រសើរគឺទុក្ខ ទុក្ខសមុទយអរិយសច្ច សេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ

ទុក្ខនិរោធអរិយសច្ច សេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរលត់ទុក្ខ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច សេចក្តីពិតដ៏ប្រសើរគឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ តថាគតដោះស្រាយនូវធម៌នោះៗ ដល់ពួកសាវកទាំងនោះ តថាគតធ្វើចិត្តរបស់ពួកសាវកទាំងនោះឲ្យត្រេកអរបានដោយការដោះស្រាយ នូវប្រស្នានោះ ម្នាលឧទាយិ! ពួកសាវករបស់តថាគត (នោះ) ឈ្មោះថាធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ហើយនៅអាស្រ័យដោយធម៌គឺព្យាករណ៍ នូវអរិយសច្ចឯណា (នេះឯងជាធម៌ទី ៤)

ម. ម. មហាសកុលុទាយិសូត្រ ២៤-១៤៣-៨៥

## ព្រះពុទ្ធជាម្ចាស់ក្នុងអតីត អនាគត, បច្ចុប្បន្ន សុទ្ធតែត្រាស់ដឹងអរិយសច្ចទាំង ៤

ម្នាលភិក្ខុទាំងឡាយ! ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយអង្គឯណានិមួយ ដែលបានត្រាស់ដឹងតាមពិត ក្នុងអតីតកាលដ៏កន្លងយូរលង់ណាស់ហើយក្តី ព្រះអរហន្តសម្មាសម្ពុទ្ធអង្គទាំងឡាយនោះៗ សុទ្ធសឹងបានត្រាស់ដឹងនូវអរិយសច្ចទាំងឡាយ ៤ ប្រការតាមពិត ។ ម្នាលភិក្ខុទាំងឡាយ! ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយអង្គឯណានិមួយ ដែលនឹងបានត្រាស់ដឹងតាមពិត ក្នុងអនាគតកាលដែលមិនទាន់មកយូរលង់ក្តី

ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយអង្គនោះ ៗ ក៏សុទ្ធសឹងទទឹងត្រាស់ដឹងនូវអរិយសច្ចទាំងឡាយ ៤ ប្រការតាមពិត ។ ម្នាលភិក្ខុទាំងឡាយ! ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ទំមួយ ដែលត្រាស់ដឹងតាមពិតក្នុងបច្ចុប្បន្នកាលឥឡូវនេះក្តី ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយអង្គនោះៗ ក៏សុទ្ធសឹងត្រាស់ដឹងនូវអរិយសច្ចទាំងឡាយ ៤ ប្រការតាមពិត ។ ចុះអរិយសច្ចសេចក្តីពិតដ៏ប្រសើរ ៤ ប្រការនេះតើដូចម្តេច ? សេចក្តីពិតដ៏ប្រសើរ ៤ ប្រការនោះគឺៈ សេចក្តីទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១ ហេតុប្រជុំកើតឡើងនៃទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១ ធម៌ជាគ្រឿងរំលត់ទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១...

ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីធ្វើសេចក្តីព្យាយាម ដើម្បីឲ្យដឹងច្បាស់ថាៈ "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ប៉ុណ្ណោះចុះ" ។

មហាវៈ សំ. ១៩-៥៤៣១-៧០៤

បទទី ៤

សេចក្តីត្រាស់ដឹងអរិយសច្ច មិនមែនជាការផុតវិស័យ

## ក្នុងអតីតកាល អនាគតកាល បច្ចុប្បន្នកាល
## សុទ្ធសឹងតែមានការប្រកាសអរិយសច្ច តាមពិត

ម្នាលភិក្ខុទាំងឡាយ ! ក្នុងអតីតកាលដ៏កន្លងវែងយូរលង់ណាស់ហើយក្តី បុគ្គលទាំងឡាយឯណានីមួយ ជាសមណៈឬជាព្រាហ្មណ៍ បានប្រកាសធម៌ដែលលោកត្រាស់ដឹងហើយតាមពិត សមណៈទាំងឡាយនោះក្តី ព្រាហ្មណ៍ទាំងឡាយនោះក្តី សុទ្ធសឹងប្រកាសនូវអរិយសច្ចទាំងឡាយ ៤ ប្រការ ដែលលោកត្រាស់ដឹងហើយដោយសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ! ក្នុងអនាគតកាលដែលមិនទាន់មកដ៏យូរលង់ក្តី បុគ្គលទាំងឡាយឯណានីមួយ ជាសមណៈឬជាព្រាហ្មណ៍ ដែលលោកនឹងប្រកាសនូវធម៌តាមពិត សមណៈទាំងឡាយនោះក្តី ព្រាហ្មណ៍ទាំងឡាយនោះក្តី ក៏សុទ្ធសឹងនឹងប្រកាសនូវអរិយសច្ចទាំងឡាយ ៤ ប្រការ ដែលលោកនឹងត្រូវត្រាស់ដឹងតាមសេចក្តីពិត ។ ម្នាលភិក្ខុទាំងឡាយ! ក្នុងបច្ចុប្បន្នកាលឥឡូវនេះក្តី បុគ្គលទាំងឡាយឯណានីមួយ ជាសមណៈឬជាព្រាហ្មណ៍ ដែលលោកប្រកាសនូវធម៌ដែលត្រាស់ដឹងតាមពិត សមណៈទាំងឡាយនោះក្តី ព្រាហ្មណ៍ទាំងឡាយនោះក្តី សុទ្ធសឹងប្រកាសនូវអរិយសច្ចទាំងឡាយ ៤ ប្រការ ដែលលោកត្រាស់ដឹងតាមសេចក្តីពិត ។ អរិយសច្ចទាំង ៤ ប្រការនោះតើដូចម្តេច ? អរិយសច្ចទាំងឡាយ ៤ ប្រការនោះគឺៈ សេចក្តីទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១ ហេតុប្រជុំកើតឡើងនៃទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១ ធម៌ជាគ្រឿងរលត់ទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១ ។ មហាវារៈ សំ. ១៩-៥ ២៣-១៦៥៤ (មាឌក)

# សេចក្ដីជូនដំណឹង

រឿងឯកសហស្រាត្រី ឬ រឿង ១ ពាន់ ១ យប់ទើបមានចុះផ្សាយក្នុងទស្សនាវដ្ដីលេខ ១០ ប្រចាំខែឧកគូបឆ្នាំ ១៩៦៥ នេះជាដើមទៅ ។ អស់លោកអ្នកដែលចូលចិត្តរឿងនេះសូមឲ្យរង់ចាំមើលក្នុងទស្សនាវដ្ដីលេខ ១០ ដែលមានសេចក្ដីផ្ដួររឿងហូរហែតគ្នា អំពីសៀវភៅរឿង ១ ពាន់ ១ យប់ ភាគទី ៩ ដែលពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពផ្សាយរួចហើយ ។

រឿង ១ ពាន់ ១ យប់ចំនួន ៩ ខ្សែដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយមកហើយ មានផ្ដួររឿងគួរឲ្យដក់ចិត្តចង់មើលជាលំដាប់ត ៗ ទៅយ៉ាងណា ភាគទី ១០-១១ ដែលយើងចាប់បោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីលេខ ១០-១១-១២ ទីនឹងនាំជាលំដាប់ត ៗ ទៅក៏សុទ្ធតែមានផ្ដួររឿងគួរឲ្យចង់ដឹងត ៗ ទៅ ជាពន្លឹកដូច្នោះដែរ ។

ដូច្នេះ យើងសូមជម្រាបអស់លោក អ្នកដែលត្រេកអរចង់ដឹងរឿង ១ ពាន់ ១ យប់ជាលំដាប់ហូរហែតទៅ សូមឲ្យចុះឈ្មោះជាទស្សនាវដ្ដីកម្ពុជសុរិយានេះចុះ ។